**អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ**
**The United Nations Framework Convention on Climate Change**

# ពិធីសារក្យូតូ

# THE KYOTO PROTOCOL

# សេចក្តីផ្តើម

នៅពេលរដ្ឋាភិបាលនៃប្រទេសនានាអនុម័តលើអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុក្នុងឆ្នាំ ១៩៩២ ពួកគេបានទទួលស្គាល់ថា អនុសញ្ញានេះអាចប្រើប្រាស់ជាមូលដ្ឋានសំរាប់ធ្វើសកម្មភាពឱ្យបានខ្លាំងក្លាទៅអនាគត ។ តាមរយៈការរៀបចំដំណើរការពិនិត្យឡើងវិញ ការពិភាក្សា និងការផ្លាស់ប្តូរពតិមានជាប្រចាំ អនុសញ្ញានេះផ្តល់ជាមូលដ្ឋានសំរាប់អនុម័តលើការសន្យាបន្ថែម ដើម្បីឆ្លើយតបនឹងរាល់ការប្រែប្រួលចំណេះដឹងផ្នែកវិទ្យាសាស្ត្រ និងឆន្ទៈនយោបាយទៅអនាគត ។

ការពិនិត្យឡើងវិញជាលើកដំបូង អំពីប្រសិទ្ធភាពអនុវត្តការសន្យារបស់បណ្តាប្រទេសអភិវឌ្ឍន៍ ត្រូវបានធ្វើឡើង តាមការស្នើសុំនៅក្នុងសម័យប្រជុំ ១ នៃសន្និសីទបណ្តាភាគី (COP-1) ដែលបានប្រព្រឹត្តទៅនៅទីក្រុងបែរឡាំង នាឆ្នាំ ១៩៩៥ ។ បណ្តាភាគីបានសំរេចថា ការសន្យារបស់បណ្តាប្រទេសអភិវឌ្ឍន៍ ដើម្បីព្យាយាមកាត់បន្ថយអេមីស្យុង (ឬការបញ្ចេញឧស្ម័ន) រហូតដល់ឆ្នាំ ២000 ឱ្យនៅត្រឹមកំរិតអេមីស្យុងឆ្នាំ ១៩៩0 ពុំទាន់គ្រប់គ្រាន់ ដើម្បីឈានទៅសំរេចគោលដៅរយៈពេលវែងនៃអនុសញ្ញានេះទេ ពោលគឺការរាំងស្កាត់ "ឥទ្ធិពលប្រកបដោយគ្រោះថ្នាក់ បណ្តាលពីសកម្មភាពមនុស្សចំពោះប្រព័ន្ធអាកាសធាតុ" ។

បណ្តារដ្ឋមន្ត្រី និងមន្ត្រីជាន់ខ្ពស់ដទៃទៀត បានឆ្លើយតបដោយអនុម័តយល់ព្រមលើ "អណត្តិទីក្រុងបែរឡាំង" (Berlin Mandate) និងបង្កើតឱ្យមាន ការចរចាបន្ថែមទៀត ដើម្បីពង្រឹងកិច្ចអនុវត្តន៍ការសន្យាដោយបណ្តាប្រទេសអភិវឌ្ឍន៍ ។ គេបានបង្កើត *ក្រុមការងារបណ្តោះអាសន្ននៃអណត្តិទីក្រុងប៊ែរឡាំង* (Ad Hoc Group on Berlin Mandate) មួយ ដើម្បីធ្វើសេចក្តីព្រាងកិច្ចព្រមព្រៀងមួយ ។ ក្រោយពីបានប្រជុំចំនួនប្រាំបីលើក ក្រុមការងារនេះបានបញ្ជូនអត្ថបទព្រាងនៃកិច្ចព្រមព្រៀងនេះ ទៅសន្និសីទបណ្តាភាគីលើកទី ៣ (COP-3) ដើម្បីចរចាសំរេច ។

នៅក្នុងព្រឹត្តិការណ៍ដ៏អធិកអធមនាទីក្រុងក្យូតូ ប្រទេសជប៉ុន នាខែធ្នូ ឆ្នាំ ១៩៩៧ មានការចូលរួមពីសំណាក់បណ្តាប្រតិភូ អ្នកសង្កេតការណ៍ និងអ្នកសារពតិមាន ប្រមាណ ១0.000 នាក់ ។ សន្និសីទនេះបានឯកភាពមតិជាទូទៅលើសេក្តីសំរេច (1/CP.3) ដើម្បីអនុម័តពិធីសារមួយ ដែលនៅក្នុងនោះបណ្តាប្រទេសឧស្សាហកម្មជឿនលឿននឹងកាត់បន្ថយអេមីស្យុងឧស្ម័នផ្ទះកញ្ចក់សរុបយ៉ាងហោច ក្នុងកំរិត ៥% ធៀបនឹងអត្រាឆ្នាំ ១៩៩0 នៅក្នុងចន្លោះឆ្នាំ ២00៨-២0១២ ខាងមុខ ។ ការសន្យាជាលក្ខណៈច្បាប់ (Legally binding commitment promises) នេះផ្តល់នូវក្តីសង្ឃឹមថា នឹងធ្វើឱ្យមានការត្រលប់បញ្រ្ចាសជាប្រវត្តិសាស្ត្រនៃអេមីស្យុង ដែលបានបញ្ចេញចោលដោយបណ្តាប្រទេសទាំងនោះ តាំងពី ១៥0 ឆ្នាំមុន មកម្ល៉េះ ។

ការចុះហត្ថលេខាលើពិធីសារក្រុងក្យូតូបានចាប់ផ្តើមនៅថ្ងៃទី ១៦ ខែមីនា ឆ្នាំ ១៩៩៨ ។ ពិធីសារនេះនឹងចូលជាធរមាននៅរយៈពេល ៩0 ថ្ងៃ ក្រោយមានការឱ្យសច្ចាប័នដោយបណ្តាភាគីនៃអនុសញ្ញានេះយ៉ាងតិចចំនួន ៥៥ ដែលក្នុងនោះត្រូវមានបណ្តាប្រទេសអភិវឌ្ឍន៍ ដែលបានបញ្ចេញអេមីស្យុងឧស្ម័នកាបូនិចយ៉ាងហោចណាស់ ៥៥% នៃអេមីស្យុងសរុបនៅឆ្នាំ ១៩៩0 ក្នុងចំណោមបណ្តាប្រទេសឧស្សាហកម្មជឿនលឿនទាំងនេះ ។ នៅក្នុងចន្លោះពេលនោះ បណ្តាភាគីក្នុងអនុសញ្ញាការស្តីពីប្រែប្រួលអាកាសធាតុ ត្រូវបន្តអនុវត្តការសន្យារបស់ខ្លួន ក្នុងក្របខ័ណ្ឌនៃអនុសញ្ញានេះ និងត្រៀមខ្លួន ដើម្បីអនុវត្តខដែលមានចែងក្នុងពិធីសារនេះ ក្រោយពេលចូលជាធរមាន ។

# មាតិកា

*បណ្តាមាត្រាក្នុងពិធីសារក្រុងក្យូតូនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ពុំមានចំណងជើងជាប់ជាមួយទេ ។ ឈ្មោះចំណងជើងដែលមានចុះនៅខាងក្រោមគ្រាន់តែជាជំនួយចង្អុលបង្ហាញដល់បណ្តាអ្នកអានតែប៉ុណ្ណោះ តែមិនមែនជាចំណែកមួយនៃអត្ថបទដើមនោះទេ ដែលនឹងមានចាប់ពីទំព័រទី ៣ តទៅ ។*


បុព្វកថា

១. និយមន័យ

២. គោលនយោបាយ និងវិធានការ

៣. ការសន្យាកំហិត និងកាត់បន្ថយបរិមាណអេមីស្យុង (Quantified emission limitation and reduction commitments)

៤. កិច្ចអនុវត្តន៍ការសន្យារួមគ្នា (Joint fulfillment of commitments)

៥. បញ្ហាវិធីសាស្ត្រ

៦. ការផ្ទេរ និងទទួលយកចំនួនឯកត្តាកាត់បន្ថយអេមីស្យុង (ការអនុវត្តន៍រួមគ្នា)

៧. ការធ្វើទំនាក់ទំនងពត៌មាន

៨. ការពិនិត្យពត៌មានឡើងវិញ

៩. ការពិនិត្យពិធីសារឡើងវិញ

១០. ការបន្តអនុវត្តការសន្យាដែលមានស្រាប់

១១. យន្តការហិរញ្ញវត្ថុ

១២. យន្តការអភិវឌ្ឍន៍ស្អាត (Clean Development Mechanism)

១៣. សន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារ

១៤. លេខាធិការដ្ឋាន

១៥. អង្គភាពជំនួយការ (Subsidiary bodies)

១៦. ដំនើរការពិគ្រោះយោបល់ពហុភាគី

១៧. ពាណិជ្ជកម្មអេមីស្យុង (Emission trading)

១៨. ករណីខកខានមិនគោរពតាមពិធីសារ (Non-compliance)

១៩. ដំណោះស្រាយជំលោះ

២០. វិសោធនកម្ម

២១. ការអនុម័ត និងវិសោធនកម្មឧបសម្ព័ន្ធ

២២. សិទ្ធិបោះឆ្នោត

២៣. កន្លែងតំកល់ឯកសារ

២៤. ហត្ថលេខា ការផ្តល់សច្ចាប័ន ការទទួលយក ការអនុម័ត ឬការសុំចូលជាសមាជិក

២៥. ការចូលជាធរមាន

២៦. ករណីលើកលែង (Reservations)

២៧. ការសុំលាលែង

២៨. អត្ថបទសំណៅដើម

ឧបសម្ព័ន្ធ ក : ឧស្ម័នផ្ទះកញ្ចក់ និងយថាប្រភេទវិស័យ/ប្រភព

ឧបសម្ព័ន្ធ ខ : ការសន្យាកំហិត និងកាត់បន្ថយបរិមាណអេមីស្យុង (Quantified emission limitation or reduction commitments) ដោយបណ្តាភាគី


*តារាងដែលមានភ្ជាប់ និងសេចក្តីសំរេចបីរបស់សន្និសីទបណ្តាភាគី មិនមែនជាផ្នែកមួយនៃពិធីសារក្រុងក្យូតូទេ ប៉ុន្តែត្រូវបានដាក់បញ្ចូលនៅទីនេះ ដោយសារវាផ្តល់ពត៌មានពាក់ព័ន្ធនឹងការអនុម័ត និងអនុវត្តន៍ពិធីសារនេះ ។*


សេចក្តីសំរេច 1/CP.3 : ការអនុម័តពិធីសារក្រុងក្យូតូនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ

សេចក្តីសំរេច 2/CP.3 : បញ្ហាវិធីសាស្ត្រទាក់ទងនឹងពិធីសារក្រុងក្យូតូ

សេចក្តីសំរេច 3/CP.3 : ការអនុវត្តន៍មាត្រា ៤ វាក្យខ័ណ្ឌ ៨ និង ៩ នៃអនុសញ្ញា

តារាង : អេមីស្យុងឧស្ម័នកាបូនិចសរុបក្នុងឆ្នាំ ១៩៩០ នៃបណ្តាភាគីក្នុងឧបសម្ព័ន្ធ ១ សំរាប់ការបំភ្លឺមាត្រា ២៥ នៃពិធីសារក្រុងក្យូតូ ។

# ពិធីសារក្យូតូ នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ

**បណ្តាប្រទេសជាភាគីក្នុងពិធីសារនេះ**

ក្នុងនាមជាភាគីក្នុងអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ចាប់ពីពេលនេះតទៅហៅកាត់ថា "អនុសញ្ញា" ។

ដើម្បីបំពេញនូវគោលបំនងចំបងនៃអនុសញ្ញានេះ ដូចមានចែងក្នុងមាត្រា ២ ។

បានឃើញខដែលមានចែងនៅក្នុងអនុសញ្ញានេះ ។

ដោយអនុវត្តតាមមាត្រា ៣ នៃអនុសញ្ញានេះ ។

អនុលោមតាមអណត្តិទីក្រុងបែរឡាំង ដែលបានអនុម័តតាមសេចក្តីសំរេច 1/CP.1 នៃសន្និសីទបណ្តាភាគីក្នុងអនុសញ្ញានេះ នៅក្នុងសម័យប្រជុំលើកទី ១ ។

**បានឯកភាពដូចតទៅ :**

## មាត្រា ១

និយមន័យដែលមានចែងក្នុងមាត្រា ១ នៃអនុសញ្ញានេះនឹងត្រូវអនុវត្តសំរាប់គោលដៅនៃពិធីសារនេះ ។

១. "សន្និសីទបណ្តាភាគី" គឺសន្និសីទនៃបណ្តាប្រទេសជាភាគីក្នុងអនុសញ្ញានេះ ។

២. "អនុសញ្ញា" គឺអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ដែលបានអនុម័តនៅទីក្រុងញូវយ៉ក នៅថ្ងៃទី ៩ ខែឧសភា ឆ្នាំ ១៩៩២ ។

៣. "ក្រុមការងារអន្តររដ្ឋាភិបាលទទួលបន្ទុកកិច្ចការប្រែប្រួលអាកាសធាតុ" (Intergovernmental Panel on Climate Change: IPCC) គឺក្រុមការងារអន្តររដ្ឋាភិបាល ទទួលបន្ទុកការងារទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងដែលបានបង្កើតឡើងរួមគ្នានៅឆ្នាំ ១៩៨៨ ដោយអង្គការឧតុនិយមពិភពលោក និងកម្មវិធីបរិស្ថានសហប្រជាជាតិ ។

៤. "ពិធីសារក្រុងម៉ុងរ៉េអាល់" គឺពិធីសារទីក្រុងម៉ុងត្រេអាល់ស្តីពីសារធាតុដែលបំផ្លាញស្រទាប់អូសូន និងដែលបានអនុម័តនៅទីក្រុងម៉ុងរ៉េអាល់ កាលពីថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ១៩៨៧ និងក្រោយមកបានកែសំរួល និងធ្វើវិសោធនកម្ម ។

៥. "ភាគីមានវត្តមាន និងបានបោះឆ្នោត" គឺបណ្តាភាគីដែលមានវត្តមាន និងដែលបានបោះឆ្នោតគាំទ្រ ឬជំទាស់ ។

៦. "បណ្តាភាគី" គឺបណ្តាភាគីក្នុងពិធីសារនេះ លើកលែងតែមានការបញ្ជាក់បន្ថែម ។

៧. "ភាគីក្នុងឧបសម្ព័ន្ធ ១" គឺភាគីដែលបានបញ្ចូលទៅក្នុងឧបសម្ព័ន្ធ ១ នៃអនុសញ្ញា ដែលអាចត្រូវធ្វើវិសោធនកម្ម ឬភាគីដែលបានធ្វើសេចក្តីជូនដំណឹង ដូចមានចែងក្នុងមាត្រា ៤ វាក្យខ័ណ្ឌ ២ (ឆ) នៃអនុសញ្ញានេះ ។

## មាត្រា ២

១. ក្នុងដំណើរអនុវត្តការសន្យាកំហិត និងកាត់បន្ថយបរិមាណអេមីស្យុង ដូចមានចែងក្នុងមាត្រា ៣ ដែលជាចំណែកមួយជំរុញការអភិវឌ្ឍន៍ដោយចិរភាព ភាគីនីមួយៗក្នុងឧបសម្ព័ន្ធ ១ ត្រូវ :

ក) អនុវត្ត និង/ឬចែងលំអិតបន្ថែមអំពីគោលនយោបាយ និងវិធានការស្របតាមកាលៈទេសៈក្នុងប្រទេស ដូចជា :

(i) បង្កើនប្រសិទ្ធិភាពនៃការប្រើប្រាស់ថាមពលនៅតាមស្ថាប័នពាក់ព័ន្ធក្នុងសេដ្ឋកិច្ចជាតិ ។

(ii) ការពារ និងធ្វើឱ្យប្រសើរឡើងនូវអាងស្រូប (sinks) និងអាងផ្ទុក (reservoirs) ឧស្ម័នផ្ទះកញ្ចក់ ដែលពុំមានចែងក្នុងពិធីសារក្រុងម៉ុងរ៉េអាល់ ដោយគិតទាំងការសន្យារបស់ប្រទេសទាំងនោះ ដូចមានចែងនៅក្នុងបណ្តាកិច្ចព្រមព្រៀងអន្តរជាតិ ពាក់ព័ន្ធនឹងបរិស្ថាន ព្រមទាំងជំរុញការគ្រប់គ្រងព្រៃឈើដោយនិរន្តភាព ការដាំព្រៃឈើ (afforestation) និងស្តារព្រៃឈើឡើងវិញ (reforestation) ។

(iii) ជំរុញរបៀបធ្វើកសិកម្មឱ្យមាននិរន្តភាព ដោយពិចារណាអំពីការប្រែប្រួលអាកាសធាតុ ។

(iv) ស្រាវជ្រាវ ជំរុញការអភិវឌ្ឍន៍ និងបង្កើនការប្រើប្រាស់ប្រភេទថាមពលថ្មី និងដែលអាចកើតឡើងវិញបាន (new and renewable forms of energy) បច្ចេកវិទ្យាស្រូបយកឧស្ម័នកាបូនិច ព្រមទាំងបច្ចេកវិទ្យាទំនើប និងថ្មីដែលមិនប៉ះពាល់ដល់បរិស្ថាន ។

(v) កាត់បន្ថយជាលំដាប់ ឬលុបបំបាត់ជាបណ្តើរៗនូវអសុក្រិតភាពនៃទីផ្សារ (market imperfection) ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ ការលើកលែងពន្ធអាករ និងការជួយឧបត្ថម្ភ សំរាប់វិស័យណា ដែលបញ្ចេញឧស្ម័នផ្ទះកញ្ចក់តាមទិន្នាការផ្ទុយពីគោលបំនងនៃអនុសញ្ញានេះ និងការប្រើប្រាស់វិធានការទីផ្សារ ។

(vi) លើកទឹកចិត្តឱ្យមានការកែទំរង់សមស្របនៅតាមវិស័យពាក់ព័ន្ធ សំដៅជំរុញការអនុវត្តន៍គោលនយោបាយ និង វិធានការកំហិត ឬកាត់បន្ថយអេមីស្យុងឧស្ម័នផ្ទះកញ្ចក់ ដែលពុំមានចែងក្នុងពិធីសារក្រុងម៉ុងរ៉េអាល់ ។

(vii) វិធានការកំហិត និង/ឬកាត់បន្ថយអេមីស្យុងឧស្ម័នផ្ទះកញ្ចក់ ដែលពុំមានចែងនៅក្នុងពិធីសារទីក្រុងម៉ុងរ៉េអាល់ ក្នុងវិស័យដឹកជញ្ជូន ។

(viii) កំហិត និង/ឬកាត់បន្ថយអេមីស្យុងឧស្ម័នមេតាន តាមរយៈការទាញយកមកប្រើវិញ (recovery) និងប្រើប្រាស់វាក្នុងផ្នែកគ្រប់គ្រងសំណល់ ក៏ដូចជានៅក្នុងផលិតកម្ម ការដឹកជញ្ជូន និងការចែកចាយថាមពល ។

ខ) ធ្វើសហប្រតិបត្តិការជាមួយភាគីនានាផ្សេងទៀត ដើម្បីបង្កើនប្រសិទ្ធិភាពគោលនយោបាយ និងវិធានការក្នុងប្រទេសរៀងខ្លួន និងរួមគ្នា ដែលបានអនុម័ត ដូចមានចែងក្នុងមាត្រានេះ និងអនុលោមតាមមាត្រា ៤ វាក្យខ័ណ្ឌ ២ (ង) (ឈ) នៃអនុសញ្ញានេះ ។ ត្រង់ចំនុចនេះ ភាគីទាំងនេះត្រូវចាត់វិធានការដើម្បីចែករំលែកបទពិសោធន៍ និងផ្លាស់ប្តូរពត៌មានអំពីគោលនយោបាយ និងវិធានការទាំងនោះ រួមទាំងបង្កើតវិធីកែលំអរបៀបប្រៀបធៀប តំលាភាព និងប្រសិទ្ធិភាព ។ នៅក្នុងសម័យប្រជុំលើកទីមួយរបស់ខ្លួន ឬក្នុងករណីបន្ទាន់ តាមតែអាចធ្វើបាន នៅពេលក្រោយមក សន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ត្រូវពិចារណារកវិធីសំរួលកិច្ចសហប្រតិបត្តិការបែបនេះ ដោយផ្អែកលើពត៌មានពាក់ព័ន្ធទាំងអស់ ។

២. ភាគីក្នុងឧបសម្ព័ន្ធ ១ ត្រូវព្យាយាមអនុវត្តកំហិត និងការកាត់បន្ថយអេមីស្យុងឧស្ម័នផ្ទះកញ្ចក់ ដែលពុំមានចែងនៅក្នុងពិធីសារក្រុងម៉ុងរ៉េអាល់ ពីសកម្មភាពអាកាសចរ និងនាវាដឹកប្រេងតាមសមុទ្រ ដោយត្រូវធ្វើការតាមរយៈអង្គការអាកាសចរស៊ីវិលអន្តរជាតិ និងអង្គការសមុទ្រអន្តរជាតិ (International Maritime Organisation) ។

៣. ភាគីក្នុងឧបសម្ព័ន្ធ ១ ត្រូវប្រឹងប្រែងអនុវត្តគោលនយោបាយ និងវិធានការដែលចែងក្នុងមាត្រានេះ ទៅតាមវិធីដែលកាត់បន្ថយផលអវិជ្ជមានបណ្តាលពីការប្រែប្រួលអាកាសធាតុ ផលប៉ះពាល់ចំពោះពាណិជ្ជកម្មអន្តរជាតិ និងចំពោះទិដ្ឋភាពសង្គម បរិស្ថាន និងសេដ្ឋកិច្ច ទៅលើបណ្តាភាគីដទៃទៀត ពិសេសភាគីជាបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និងដែលមានចែងនៅក្នុងមាត្រា ៤ វាក្យខ័ណ្ឌ ៨ និង ៩ នៃអនុសញ្ញា ព្រមទាំងត្រូវផ្អែកលើមាត្រា ៣ នៃអនុសញ្ញានេះ ។ ក្នុងករណីសមស្រប សន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ អាចចាត់វិធានការបន្ថែមទៀត ដើម្បីជំរុញការអនុវត្តន៍ខ ដែលមានចែងក្នុងវាក្យខ័ណ្ឌនេះ ។

៤. ប្រសិនបើមានការកំនត់ថា ការសំរបសំរួលគោលនយោបាយ និងវិធានការណាមួយក្នុងវាក្យខ័ណ្ឌ ១ (ក) ខាងលើអាចផ្តល់ផលប្រយោជន៍ ដោយពិចារណាផងដែរពីលក្ខខ័ណ្ឌ និងផលដែលអាចកើតមានខុសគ្នាចំពោះប្រទេសនីមួយៗ សន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ត្រូវពិចារណារកវិធី និងមធ្យោបាយ ដើម្បីចែងឱ្យបានលំអិតអំពីការសំរបសំរួលគោលនយោ-បាយ និងវិធានការទាំងនោះ ។

## មាត្រា ៣

១. បណ្តាភាគីក្នុងឧបសម្ព័ន្ធ ១ ត្រូវធានារៀងៗខ្លួន និងរួមគ្នាថា បរិមាណសរុបនៃឧស្ម័នកាបូនិចកើតពីសកម្មភាពមនុស្ស សមមូលនឹងអេមីស្យុងនៃបណ្តាឧស្ម័នផ្ទះកញ្ចក់ចែងក្នុងឧបសម្ព័ន្ធ A មិនលើសពីបរិមាណកំនត់ (assigned amounts) របស់ភាគីទាំងនោះ ដែលគណនាអនុលោមតាមការសន្យាកំហិត និងកាត់បន្ថយបរិមាណអេមីស្យុងចែងក្នុងឧបសម្ព័ន្ធ B និងអនុលោមតាមខ ដែលមានក្នុងមាត្រានេះ ដោយត្រូវផ្អែកលើគោលដៅកាត់បន្ថយបរិមាណអេមីស្យុងសរុបនៃឧស្ម័នទាំងនោះ ឱ្យបានយ៉ាងហោចណាស់ ៥% នៅក្រោមកំរិតអេមីស្យុងឆ្នាំ ១៩៩០ នៅក្នុងចន្លោះពេលសន្យា ឆ្នាំ ២០០៨-២០១២ ។

២. រហូតដល់ឆ្នាំ ២០០៥ ភាគីក្នុងឧបសម្ព័ន្ធ ១ ត្រូវបង្ហាញឱ្យឃើញនូវភាពរីកចំរើនក្នុងកិច្ចអនុវត្តន៍ការសន្យារបស់ខ្លួនតាមពិធីសារនេះ ។

៣. ការប្រែប្រួលសុទ្ធនៃអេមីស្យុងឧស្ម័នផ្ទះកញ្ចក់ពីប្រភពផ្សេងៗ និងការស្រូបយកតាមរយៈអាងស្រូបកាបូន បណ្តាលពីសកម្មភាពមនុស្សដោយផ្ទាល់ ដូចជាការផ្លាស់ប្តូររបៀបប្រើប្រាស់ដី និងព្រៃឈើ ដែលកើតពីការដាំព្រៃឈើ ការស្តារព្រៃឈើ និងការបាត់បង់ព្រៃឈើ តាំងពីឆ្នាំ ១៩៩០ រហូតមក អាចចាត់ទុកជាការប្រែប្រួលសន្និធិកាបូន ដែលអាចផ្ទៀងផ្ទាត់បាន នៅក្នុងរយៈពេលនៃការសន្យា ហើយនឹងត្រូវប្រើប្រាស់សំរាប់ផ្ទៀងផ្ទាត់ប្រសិទ្ធិភាពអនុវត្តការសន្យា ដែលចែងក្នុងមាត្រានេះសំរាប់ភាគីនីមួយៗ ក្នុងឧបសម្ព័ន្ធ ១ ។ ត្រូវធ្វើសេចក្តីរាយការណ៍ និងពិនិត្យឡើងវិញ តាមទំរង់ដែលមានតំលាភាព និងដែលអាចផ្ទៀងផ្ទាត់បាន នូវអេមីស្យុងឧស្ម័នផ្ទះកញ្ចក់ពីប្រភពផ្សេងៗ និងការស្រូបយកតាមរយៈអាងស្រូបកាបូនបណ្តាលពីសកម្មភាពពាក់ព័ន្ធទាំងនោះ អនុលោមតាមមាត្រា ៧ និង ៨ ។

៤. ដើម្បីជាមូលដ្ឋានសំរាប់ការពិចារណារបស់អង្គភាពជំនួយការផ្តល់យោបល់វិទ្យាសាស្រ្ត និងបច្ចេកវិទ្យា មុនពេលបើកសម័យប្រជុំទី ១ នៃសន្និសីទបណ្តាភាគី សំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ភាគីនីមួយៗក្នុងឧបសម្ព័ន្ធ ១ ត្រូវផ្តល់ទិន្នន័យសំរាប់រៀបចំកំនត់កំរិតសន្និធិកាបូនឆ្នាំ ១៩៩០ និងសំរាប់ផ្តល់លទ្ធភាពប៉ាន់ប្រមាណអំពីការប្រែប្រួលសន្និធិកាបូន សំរាប់បណ្តាឆ្នាំបន្តបន្ទាប់ទៀត ។ នៅក្នុងសម័យប្រជុំលើកទី ១ ឬក្នុងករណីបន្ទាន់តាមតែអាចធ្វើបាននៅពេលក្រោយមកទៀត សន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ត្រូវសំរេចកំនត់បណ្តាសកម្មភាពបន្ថែមទៀតបង្កដោយមនុស្ស ពាក់ព័ន្ធនឹងការប្រែប្រួលអេមីស្យុងឧស្ម័នផ្ទះកញ្ចក់ពីប្រភពផ្សេងៗ និងការចាប់យកតាមរយៈអាងស្រូបកាបូន នៅក្នុងដីកសិកម្ម និងក្នុងការផ្លាស់ប្តូររបៀបប្រើប្រាស់ដី និងព្រៃឈើ ដោយផ្អែកលើ វិធី បទបញ្ជា និងគោលការណ៍ណែនាំ ដើម្បីដាក់បញ្ចូលបន្ថែម ឬកាត់ចេញពីបញ្ជីបរិមាណកំណត់សំរាប់បណ្តាភាគីក្នុងឧបសម្ព័ន្ធ ១ ដោយគិតទាំងភាពមិនប្រាកដប្រជា តំលាភាពក្នុងសេចក្តីរាយការណ៍ ភាពអាចផ្ទៀងផ្ទាត់បាន វិធីសាស្រ្តស្រាវជ្រាវ របស់ក្រុមការងារអន្តររដ្ឋាភិបាលទទួលបន្ទុកកិច្ចការប្រែប្រួលបរិយាកាស បណ្តាសេចក្តីណែនាំពីអង្គភាពជំនួយការវិទ្យាសាស្រ្ត និងបច្ចេកវិទ្យា ស្របតាមមាត្រា ៥ និងសេចក្តីសំរេចនៃសន្និសីទបណ្តាភាគី ។ សេចក្តីសំរេចបែបនេះនឹង ត្រូវអនុវត្តនៅដំណាក់កាលទី ២ ឬដំណាក់កាលបន្ទាប់ទៀតនៃការសន្យា ។ ភាគីនីមួយៗអាចមានជំរើសដើម្បីអនុវត្តសេចក្តីសំរេចបែបនេះ ដើម្បីគ្រប់គ្រងសកម្មភាពបន្ថែមបង្កដោយមនុស្ស នៅក្នុងដំនាក់កាលទី ១ នៃការសន្យាអនុវត្ត ប្រសិនបើសកម្មភាពទាំងនោះបានចាប់ផ្តើម មានតាំងតែពីឆ្នាំ ១៩៩០ មក ។

៥. បណ្តាភាគីក្នុងឧបសម្ព័ន្ធ ១ ដែលជាប្រទេសក្នុងសេដ្ឋកិច្ចអន្តរកាល និងដែលមានឆ្នាំ ឬចន្លោះពេលមូលដ្ឋាន (base year or period) ត្រូវបានកំនត់ អនុលោមតាមសេចក្តីសំរេច 9/CP.2 នៃសន្និសីទបណ្តាភាគីនៅក្នុងសម័យប្រជុំលើកទី ២ របស់ខ្លួន ត្រូវប្រើឆ្នាំឬចន្លោះពេលមូលដ្ឋាននោះ ដើម្បីអនុវត្តការសន្យារបស់ខ្លួនទៅតាមមាត្រានេះ ។ បណ្តាភាគីណាមួយផ្សេងទៀតក្នុងឧបសម្ព័ន្ធ ១ ដែលស្ថិតក្នុងសេដ្ឋកិច្ចអន្តរកាល តែពុំបានដាក់ជូនរបាយការណ៍ជាតិ តាមមាត្រា ១២ នៃអនុសញ្ញា ក៏អាចធ្វើសេចក្តីជូនដំណឹងទៅសន្និសីទបណ្តាភាគី សំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះថា ប្រទេសទាំងនោះមានបំណងប្រកាន់យកឆ្នាំ ឬចន្លោះពេលមូលដ្ឋានផ្សេងពីឆ្នាំ ១៩៩០ សំរាប់អនុវត្តការសន្យារបស់គេតាមមាត្រានេះ ។ សន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ត្រូវធ្វើសេចក្តីសំរេចអនុម័តលើសេចក្តីជូនដំណឹងបែបនេះ ។

៦. ដោយយោងតាមមាត្រា ៤ វាក្យខ័ណ្ឌ ៦ នៃអនុសញ្ញានេះ សន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ត្រូវអនុញ្ញាតឱ្យមានការអនុគ្រោះមួយចំនួនដល់បណ្តាភាគីក្នុងឧបសម្ព័ន្ធ ១ ដែលជាប្រទេសស្ថិតក្នុងសេដ្ឋកិច្ចអន្តរកាល ក្នុងកិច្ចអនុវត្តការសន្យារបស់ខ្លួនតាមមាត្រានានាក្នុងពិធីសារនេះ លើកលែងតែមាត្រានេះចេញ ។

៧. នៅក្នុងដំនាក់កាលទី ១ នៃកិច្ចអនុវត្តន៏ការសន្យាកំហិត និងកាត់បន្ថយអេមីស្យុងឆ្នាំ ២០០៨-២០១២ បរិមាណកំនត់សំរាប់ភាគីនីមួយៗ ក្នុងឧបសម្ព័ន្ធ ១ ត្រូវតែស្មើនឹងភាគរយនៃអេមីស្យុងឧស្ម័នកាបូនិចសរុប បណ្តាលពីសកម្មភាពមនុស្ស ដែលមានចែងក្នុងឧបសម្ព័ន្ធ B សមមូលនឹងអេមីស្យុងឧស្ម័នផ្ទះកញ្ចក់ចែងក្នុងឧបសម្ព័ន្ធ B ក្នុងឆ្នាំ ១៩៩០ ឬ ឆ្នាំឬចន្លោះពេលមូលដ្ឋាន កំនត់តាមវាក្យខ័ណ្ឌ៥ខាងលើ ដោយគុណនឹង ៥ ។ បណ្តាភាគីក្នុងឧបសម្ព័ន្ធ ១ ដែលមានសកម្មភាពបង្កឱ្យប្រែប្រួលការប្រើប្រាស់ដី និងព្រៃឈើ បង្កើតជាប្រភពសុទ្ធនៃអេមីស្យុងឧស្ម័នផ្ទះកញ្ចក់ក្នុងឆ្នាំ ១៩៩០ ត្រូវបញ្ចូលទៅក្នុងឆ្នាំ ឬចន្លោះពេលមូលដ្ឋានអេមីស្យុងឆ្នាំ ១៩៩០ របស់ខ្លួន នូវឧស្ម័នកាបូនិចសរុបបណ្តាលពីសកម្មភាពមនុស្ស សមមូលនឹងបណ្តាអេមីស្យុងសរុបតាមបណ្តាប្រភពនានា ដកនឹងបរិមាណស្រូបយកតាមរយៈអាងស្រូបកាបូនក្នុងឆ្នាំ ១៩៩០ បណ្តាលពីសកម្មភាពប្រែប្រួលក្នុងការប្រើប្រាស់ដី សំរាប់ធ្វើជាមូលដ្ឋាននៃការគណនាបរិមាណកំនត់ (assigned amount) ។

៨. ភាគីនីមួយៗក្នុងឧបសម្ព័ន្ធ ១ អាចប្រកាន់យកឆ្នាំ ១៩៩៥ ជាឆ្នាំមូលដ្ឋាន សំរាប់ការគណនាឧស្ម័នអ៊ីដ្រូភ្លុយអរ៉ូកាបូន ឧស្ម័នពែរភ្លុយអរ៉ូកាបូន និងឧស្ម័នស៊ុលភួអិចសាភ្លុយអរីត យោងតាមវាក្យខ័ណ្ឌ ៧ ខាងលើ ។

៩. ការសន្យាសំរាប់ដំណាក់កាលបន្ទាប់សំរាប់បណ្តាភាគីក្នុងឧបសម្ព័ន្ធ ១ ត្រូវកំនត់តាមវិសោធនកម្មលើឧបសម្ព័ន្ធ B ក្នុងពិធីសារនេះ ដែលនឹងត្រូវអនុម័តអនុលោមតាមបណ្តាខចែងក្នុងមាត្រា ២១ វាក្យខ័ណ្ឌ ៧ ។ សន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ត្រូវពិចារណាលើការសន្យាបែបនេ ះនៅក្នុងកំឡុងពេលយ៉ាងហោចណាស់ ៧ ឆ្នាំ មុនពេលចុងបញ្ចប់នៃដំណាក់កាលសន្យាទី ១ ដែលមានយោងនៅក្នុងវាក្យខ័ណ្ឌ ១ ខាងលើ ។

១០. ចំនួនឯកត្តានៃអេមីស្យុងត្រូវកាត់បន្ថយ (emission reduction units) ឬចំណែកមួយនៃបរិមាណកំនត់ ដែលភាគីមួយទទួលយកពីភាគីមួយផ្សេងទៀត អនុលោមតាមខដែលមានចែងក្នុងមាត្រា ៦ ឬមាត្រា ១៧ ត្រូវបូកបន្ថែមជាមួយបរិមាណកំនត់សំរាប់ភាគីដែលជាអ្នកទទួលយកនោះ ។

១១. ចំនួនឯកត្តានៃអេមីស្យុងត្រូវកាត់បន្ថយ ឬចំណែកណាមួយនៃបរិមាណកំនត់ ដែលភាគីមួយផ្ទេរទៅឱ្យភាគីមួយផ្សេងទៀត អនុលោមតាមខដែលមានចែងក្នុងមាត្រា ៦ ឬមាត្រា ១៧ ត្រូវតែកាត់ចេញពីបរិមាណកំនត់សំរាប់ភាគីជាអ្នកផ្ទេរនោះ ។

១២. ការកាត់បន្ថយណាមួយនៃអេមីស្យុងដែលបានបញ្ជាក់ថាត្រឹមត្រូវ ដែលភាគីណាមួយទទួលបានពីភាគីមួយផ្សេងទៀត អនុលោមតាមបណ្តាខចែងក្នុងមាត្រា ១២ ត្រូវបូកបន្ថែមជាមួយបរិមាណកំនត់សំរាប់កាត់បន្ថយរបស់ភាគីទទួលយកនោះ ។

១៣. បើនៅក្នុងដំណាក់កាលនៃការសន្យា អេមីស្យុងនៃភាគីណាមួយក្នុងឧបសម្ព័ន្ធ ១ មានបរិមាណតិចជាងបរិមាណកំនត់តាមមាត្រានេះ ភាគីនោះអាចធ្វើសេចក្តីស្នើដើម្បីដាក់បរិមាណខុសគ្នានេះទៅក្នុងបរិមាណកំនត់របស់ភាគីនោះ សំរាប់ដំនាក់កាលបន្ទាប់នៃការសន្យា ។

១៤. ភាគីនីមួយៗក្នុងឧបសម្ព័ន្ធ ១ត្រូវប្រឹងប្រែងអនុវត្តការសន្យាចែងក្នុងវាក្យខ័ណ ១ ខាងលើ តាមរបៀបដែលកាត់បន្ថយផលប៉ះពាល់ចំពោះសង្គម បរិស្ថាន និងសេដ្ឋកិច្ចរបស់ភាគីជាប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសផលប៉ះពាល់ដែលមានចែងក្នុងមាត្រា ៤ វាក្យខ័ណ្ឌ ៨ និង ៩ នៃអនុសញ្ញា ។ ស្របគ្នានឹងសេចក្តីសំរេចមួយចំនួននៃសន្និសីទបណ្តាភាគី ពាក់ព័ន្ធនឹងការអនុវត្តវាក្យខ័ណ្ឌទាំងនោះ នៅក្នុងសម័យប្រជុំលើកទី ១ របស់ខ្លួន សន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ត្រូវពិចារណាបណ្តាសកម្មភាព ចាំបាច់សំរាប់ កាត់បន្ថយផលប៉ះពាល់បណ្តាលពីការប្រែប្រួលអាកាសធាតុ និង/ឬផលប៉ះពាល់បណ្តាលពីវិធានការនានា ទៅលើបណ្តាភាគីដែលមានចែងក្នុងបណ្តាវាក្យខ័ណ្ឌទាំងនោះ ។ ក្នុងចំនោមបញ្ហាដែលត្រូវពិចារណាត្រូវមាន ការបង្កើតមូលនិធិ ការធានារ៉ាប់រង និងការផ្ទេរបច្ចេកវិទ្យា ។

## មាត្រា ៤

១. បណ្តាភាគីក្នុងឧបសម្ព័ន្ធ ១ ដែលមានចុះកិច្ចព្រមព្រៀងបំពេញការសន្យារបស់ខ្លួនរួមគ្នាតាមមាត្រា ៣ ត្រូវតែចាត់ទុកថាបានបំពេញការសន្យាតែក្នុងករណីណា ដែលបរិមាណឧស្ម័នកាបូនិចសរុបបណ្តាលពីសកម្មភាពមនុស្សរួមមូលនឹងអេមីស្យុងនៃបណ្តាឧស្ម័នផ្ទះកញ្ចក់ ចែងក្នុងឧបសម្ព័ន្ធ A មានមិនលើសពីបរិមាណកំនត់ដែលគណនាអនុលោមតាមការសន្យាកំហិត និងការកាត់បន្ថយអេមីស្យុងរបស់ប្រទេសក្នុងកិច្ចព្រមព្រៀងនោះ ដែលមានចែងក្នុងឧបសម្ព័ន្ធ B និងដោយអនុលោមតាមខ ដែលមានក្នុងមាត្រា ៣ ។ កំរិតអេមីស្យុង សំរាប់បណ្តាភាគីក្នុងកិច្ចព្រមព្រៀងទាំងនោះ ត្រូវតែមានចែងនៅក្នុងកិច្ចព្រមព្រៀងនោះ ។

២. បណ្តាភាគីក្នុងកិច្ចព្រមព្រៀងបែបនេះ ត្រូវធ្វើសេចក្តីជូនដំណឹងទៅលេខាធិការដ្ឋាន អំពីលក្ខខណ្ឌនៃកិច្ចព្រមព្រៀង នៅថ្ងៃដែលដាក់តំកល់លិខិតូបករណ៍ផ្តល់សច្ចាប័ន ឯកសារទទួលស្គាល់ អនុម័ត ឬសុំចូលជាសមាជិកពិធីសារនេះ ។ លេខាធិការដ្ឋានត្រូវធ្វើសេចក្តីជូនដំនឹង ឆ្លើយតបទៅបណ្តាភាគី និងហត្ថលេខីក្នុងអនុសញ្ញានេះ អំពីលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនោះ ។

៣. កិច្ចព្រមព្រៀងបែបនេះណាមួយត្រូវស្ថិតនៅជាធរមានសំរាប់ដំណាក់កាលមួយនៃការសន្យាដូចមានចែងក្នុងមាត្រា ៣ វាក្យខ័ណ្ឌ ៧ ។

៤. ប្រសិនបើបណ្តាភាគីធ្វើសកម្មភាពបែបនេះរួមគ្នា ក្នុងក្របខ័ណ្ឌនៃ និងជាមួយអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ រាល់ការកែប្រែណាមួយនៅក្នុងរចនាសម្ព័ន្ធរបស់អង្គការនេះ ក្រោយពីអនុម័តពិធីសារនេះ នឹងមិនប៉ះពាល់ដល់ការសន្យាដែលមានស្រាប់ក្នុងក្របខ័ណ្ឌនៃពិធីសារនេះទេ ។ រាល់ការកែប្រែណាមួយនៅក្នុងរចនាសម្ព័ន្ធរបស់អង្គការនេះ នឹងមានអនុភាពសំរាប់តែបណ្តាការសន្យាតាមមាត្រា ៣ ដែលបានអនុម័តក្រោយពេលមានការកែប្រែនោះ ។

៥. ក្នុងករណីដែលបណ្តាភាគីក្នុងកិច្ចព្រមព្រៀងមិនអាចសំរេចបាននូវការកាត់បន្ថយអេមីស្យុងសារុបរបស់ខ្លួនតាមការកំនត់ ភាគីនីមួយៗក្នុងកិច្ចព្រមព្រៀងនោះ ត្រូវទទួលខុសត្រូវរៀងៗខ្លួនចំពោះចំណែកអេមីស្យុងរបស់ខ្លួនដែលបានចែងនៅក្នុងកិច្ចព្រមព្រៀងនោះ ។

៦. ប្រសិនបើបណ្តាភាគីធ្វើសកម្មភាពបែបនេះរួមគ្នាក្នុងក្របខ័ណ្ឌ និងជាមួយអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ដែលអង្គការនោះក៏ជាភាគីក្នុងពិធីសារនេះដែរ រដ្ឋនីមួយៗជាសមាជិកនៃអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់នោះ ត្រូវធ្វើសកម្មភាពរៀងខ្លួន និងជាមួយអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ដោយអនុលោមតាមមាត្រា ២៤ និងក្នុងករណីមិនអាចសំរេចបាននូវការកាត់បន្ថយកំរិតអេមីស្យុងសរុប ត្រូវទទួលខុសត្រូវចំពោះចំណែកអេមីស្យុងរបស់ខ្លួន ដូចដែលមានចែងក្នុងមាត្រានេះ ។

## មាត្រា ៥

១. ភាគីនីមួយៗក្នុងឧបសម្ព័ន្ធ ១ ត្រូវមានរួចជាស្រេចនូវប្រព័ន្ធសំរាប់ប្រទេសខ្លួន ដើម្បីប៉ាន់ប្រមាណអេមីស្យុងបណ្តាលពីសកម្មភាពមនុស្សពីប្រភពផ្សេងៗ និងការចាប់យកតាមរយៈអាងស្រូបកាបូននៃឧស្ម័នផ្ទះកញ្ចក់គ្រប់ប្រភេទ ដែលពុំមានចែងក្នុងពិធីសារក្រុងម៉ុងរ៉េអាល់ ឱ្យបានយ៉ាងយឺតបំផុតក្នុងរយៈពេលមួយឆ្នាំ មុនពេលចាប់ផ្តើមដំនាក់កាលទីមួយនៃការសន្យា ។ គោលការណ៍ណែនាំសំរាប់ប្រព័ន្ធជាតិបែបនេះ ដែលមានរួមបញ្ចូលវិធីសាស្ត្រចែងក្នុងវាក្យខ័ណ្ឌ ២ ខាងក្រោម ត្រូវតែមានការសំរេចទទួលស្គាល់ដោយសន្និសីទបណ្តាភាគី សំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ នៅក្នុងសម័យប្រជុំទី ១ របស់ខ្លួន ។

២. វិធីសាស្ត្រប៉ាន់ប្រមាណអេមីស្យុងបណ្តាលពីសកម្មភាពមនុស្សពីប្រភពនានា និងការចាប់យកតាមរយៈការស្រូបឧស្ម័នផ្ទះកញ្ចក់គ្រប់ប្រភេទ ដែលពុំមានក្នុងពិធីសារក្រុងម៉ុងរ៉េអាល់ ត្រូវតែជាវិធីសាស្ត្រ ដែលមានការទទួលស្គាល់ដោយក្រុមការងារអន្តររដ្ឋាភិបាលទទួលបន្ទុកកិច្ចការប្រែប្រួលអាកាសធាតុ និងមានការឯកភាពដោយសន្និសីទបណ្តាភាគីក្នុងសម័យប្រជុំទី ៣ របស់ខ្លួន ។ ក្នុងករណីដែលមិនមានប្រើប្រាស់វិធីសាស្ត្រខាងលើ គេត្រូវធ្វើការកែតំរូវសមស្រប អនុលោមតាមវិធីសាស្ត្រដែលមានការឯកភាពដោយ

សន្និសីទភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះនៅក្នុងសម័យប្រជុំលើកទី ១ របស់ខ្លួន ។ ផ្អែកលើមូលដ្ឋាននៃការងាររបស់ក្រុមការងារអន្តររដ្ឋាភិបាលទទួលបន្ទុកកិច្ចការប្រែប្រួលអាកាសធាតុ និងយោបល់វិទ្យាសាស្ត្រនិងបច្ចេកវិទ្យាពីអង្គភាពជំនួយការសន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ត្រូវពិនិត្យ និងក្នុងករណីសមស្រប ត្រូវកែសំរួលជាទៀងទាត់នូវវិធីសាស្ត្រ និងកំណែតំរូវ ដោយផ្អែកលើរាល់សេចក្តីសំរេចពាក់ព័ន្ធរបស់សន្និសីទបណ្តាភាគី ។ រាល់ការកែសំរួលវិធីសាស្ត្រ និងកំណែតំរូវ ត្រូវធ្វើតែក្នុងករណី ដើម្បីផ្ទៀងផ្ទាត់រវាងប្រសិទ្ធិភាពអនុវត្តការសន្យាតាមមាត្រា ៣ សំរាប់ចន្លោះពេលនៃការសន្យា ក្រោយពីមានការកែសំរួល ។

៣. សក្តានុពលនៃកំនើនកំដៅពិភពលោក (global warming potentials) ដែលប្រើប្រាស់សំរាប់គណនាឧស្ម័នកាបូនិច សមមូលនឹងអេមីស្យុងដោយសកម្មភាពមនុស្សពីបណ្តាប្រភពផ្សេងៗ និងការចាប់យកតាមរយៈការស្រូបបណ្តាឧស្ម័នផ្ទះកញ្ចក់ចែងក្នុងឧបសម្ព័ន្ធ A ត្រូវតែជាបណ្តាសក្តានុពល ដែលមានការទទួលស្គាល់ដោយក្រុមការងារអន្តររដ្ឋាភិបាលទទួលបន្ទុកកិច្ចការប្រែប្រួលអាកាសធាតុ និងឯកភាពដោយសន្និសីទបណ្តាភាគ ក្នុងសម័យប្រជុំទី ៣ របស់ខ្លួន ។ ផ្អែកលើមូលដ្ឋាននៃការងាររបស់ក្រុមការងារអន្តររដ្ឋាភិបាលទទួលបន្ទុកកិច្ចការប្រែប្រួលអាកាសធាតុ ព្រមទាំងយោបល់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ពីអង្គភាពជំនួយការ សន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះត្រូវពិនិត្យ និងក្នុងករណីសមស្រប ត្រូវកែសំរួលសក្តានុពលកំនើនកំដៅពិភពលោកនៃឧស្ម័នផ្ទះកញ្ចក់បែបនោះ ដោយផ្អែកលើគ្រប់សេចក្តីសំរេចពាក់ព័ន្ធរបស់សន្និសីទបណ្តាភាគី ។ រាល់ការកែសំរួលសក្តានុពលកំនើនកំដៅពិភពលោក ត្រូវធ្វើតែនៅក្នុងករណី ដើម្បីផ្ទៀងផ្ទាត់រវាងប្រសិទ្ធិភាពអនុវត្តការសន្យាតាមមាត្រា ៣ សំរាប់ចន្លោះពេលនៃការសន្យាក្រោយពីមានការកែសំរួល ។

## មាត្រា ៦

១. ដើម្បីបំពេញការសន្យាតាមមាត្រា ៣ រាល់ភាគីក្នុងឧបសម្ព័ន្ធ ១ អាចផ្ទេរ ឬទទួលយកពីភាគីមួយផ្សេងទៀត នូវចំនួនឯកត្តាណាមួយនៃអេមីស្យុងដែលត្រូវកាត់បន្ថយ តាមរយៈគំរោងការដែលមានគោលដៅកាត់បន្ថយអេមីស្យុងពីសកម្មភាពមនុស្សពីប្រភពនានា ឬបង្កើនការចាប់យកតាមរយៈអាងស្រូបឧស្ម័នផ្ទះកញ្ចក់នៅក្នុងវិស័យសេដ្ឋកិច្ច តែនៅក្នុងករណីដែល :

(ក) គំរោងការបែបនោះទទួលការឯកភាពពីបណ្តាភាគីពាក់ព័ន្ធ

(ខ) គំរោងការបែបនេះផ្តល់នូវការកាត់បន្ថយអេមីស្យុងពីប្រភពនានា ឬបង្កើនការចាប់យកតាមរយៈអាងស្រូបកាបូន បន្ថែមពីលើបណ្តាគំរោងធម្មតាដែលអាចនឹងអនុវត្ត

(គ) ពុំទទួលយកចំនួនឯកត្តាណាមួយនៃអេមីស្យុងដែលត្រូវកាត់បន្ថយ ប្រសិនបើវាពុំគោរពតាមកាតព្វកិច្ចចែងក្នុងមាត្រា ៥ និង ៧

(ឃ) ការទទួលយកចំនួនឯកត្តាណាមួយនៃអេមីស្យុងដែលត្រូវកាត់បន្ថយ ត្រូវតែជាការបន្ថែមលើសកម្មភាពក្នុងប្រទេស ដើម្បីបំពេញការសន្យាចែងក្នុងមាត្រា ៣ ។

២. នៅក្នុងសម័យប្រជុំលើកទី ១ របស់ខ្លួន ឬក្នុងពេលបន្ទាន់តាមតែអាចធ្វើបាននៅពេលក្រោយមកទៀត សន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ អាចធ្វើការចែងឱ្យបានលំអិតបន្ថែមសំរាប់អនុវត្តមាត្រានេះ រួមទាំងដើម្បីផ្ទៀងផ្ទាត់ និងដើម្បីធ្វើសេក្តីរាយការណ៍ ។

៣. ភាគីណាមួយក្នុងឧបសម្ព័ន្ធ ១ ក្រោមការទទួលខុសត្រូវរបស់ខ្លួន អាចផ្តល់សិទ្ធិដល់អង្គភាពស្របច្បាប់មួយចំនួនដើម្បីចូលរួមក្នុងសកម្មភាពឈានទៅបង្កើត ផ្ទេរ ឬទទួលយកចំនួនឯកត្តាណាមួយនៃអេមីស្យុងដែលត្រូវកាត់បន្ថយ តាមមាត្រានេះ ។

៤. ប្រសិនបើមានសំនួរមួយចំនួនពាក់ព័ន្ធនឹងការអនុវត្តន៏របស់ភាគីណាមួយក្នុងឧបសម្ព័ន្ធ ១ ស្តីពីតំរូវការដែលមានយោងក្នុងមាត្រានេះត្រូវបានធ្វើអត្តសញ្ញាណអនុលោមទៅតាមខពាក់ព័ន្ធក្នុងមាត្រា ៨ ការផ្ទេរ ឬទទួលយកចំនួនឯកត្តាណាមួយនៃអេមីស្យុងដែលត្រូវកាត់បន្ថយ អាចត្រូវបន្តបានក្រោយពេលដែលសំនួរនោះត្រូវបានធ្វើអត្តសញ្ញាណ និងក្នុងករណីដែលចំនួនឯកត្តាណាមួយខាងលើមិនមានប្រើប្រាស់ដោយភាគីណាមួយ ដើម្បីបំពេញការសន្យារបស់ខ្លួនតាមមាត្រាពរហូតដល់បានដោះស្រាយបញ្ហាទាំងនោះរួចរាល់ ។

## មាត្រា ៧

១. ភាគីក្នុងឧបសម្ព័ន្ធ ១ ត្រូវដាក់បញ្ចូលនៅក្នុងរបាយការណ៍សារពើភ័ណ្ឌប្រចាំឆ្នាំរបស់ខ្លួន អំពីអេមីស្យុងដោយសកម្មភាពមនុស្សពីប្រភពនានា និងការចាប់យកដោយអាងស្រូបកាបូននៃឧស្ម័នផ្ទះកញ្ចក់ ដែលពុំមានចែងក្នុងពិធីសារក្រុងម៉ុងរ៉េអាល់ និងដែលត្រូវដាក់ជូន អនុលោមតាមគ្រប់សេចក្តីសំរេចនៃសន្និសីទបណ្តាភាគី នូវបណ្តាពិតមានបន្ថែមចាំបាច់ដើម្បីបញ្ជាក់ពី កិច្ចអនុវត្តន៏ការសន្យាចែងក្នុងមាត្រា ៣ សំរាប់ការធ្វើសេចក្តីសំរេចអនុលោមតាមវាក្យខ័ណ្ឌ ៤ ខាងក្រោម ។

២. ភាគីនីមួយៗក្នុងឧបសម្ព័ន្ធ ១ ត្រូវដាក់បញ្ចូលក្នុងរបាយការណ៍ជាតិប្រចាំឆ្នាំរបស់ខ្លួន ដែលត្រូវដាក់ជូនអនុលោមតាមមាត្រា ១២ នៃអនុសញ្ញានេះ នូវព័ត៌មានបន្ថែមចាំបាច់ ដើម្បីបញ្ជាក់ពីលទ្ធផលនៃកិច្ចអនុវត្តន៍ការសន្យាតាមពិធីសារនេះ សំរាប់ការធ្វើសេចក្តីសំរេចអនុលោមតាមវាក្យខ័ណ្ឌ ៤ ខាងក្រោម ។

៣. ភាគីនីមួយៗក្នុងឧបសម្ព័ន្ធ ១ ត្រូវដាក់ជូនប្រចាំឆ្នាំនូវព័ត៌មានតាមការចែងក្នុងវាក្យខ័ណ្ឌ ១ ខាងលើ ដោយចាប់ផ្តើមពីរបាយការណ៍សារពើភ័ណ្ឌលើកទី ១ ដែលជាប្រការចាំបាច់នៅក្នុងក្របខ័ណ្ឌនៃអនុសញ្ញា សំរាប់ដំនាក់កាលទី ១ នៃការសន្យា ក្រោយពីពិធីសារនេះចូលជាធរមានសំរាប់ភាគីនោះ ។ ភាគីនោះត្រូវដាក់ជូននូវព័ត៌មានចាំបាច់តាមវាក្យខ័ណ្ឌ ២ ខាងលើ ជាចំណែកមួយនៃរបាយការណ៍ជាតិដំបូង ដែលជាប្រការចាំបាច់នៅក្នុងក្របខ័ណ្ឌនៃអនុសញ្ញានេះ ក្រោយពេលពិធីសារនេះចូលជាធរមានសំរាប់ភាគីនោះ និងក្រោយពីមានការអនុម័តឯកភាពលើគោលការណ៍ ដែលមានចែងក្នុងវាក្យខ័ណ្ឌ ៤ ខាងក្រោម ។ សន្និសីទបណ្តាភាគីសំរាប់ជាការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះត្រូវកំនត់ពីចន្លោះពេលដែលត្រូវដាក់ជូននូវរបាយការណ៍ចាំបាច់តាមមាត្រានេះ ដោយត្រូវគិតផងដែរអំពីកាលបរិច្ឆេទនៃការដាក់ជូនរបាយការណ៍ជាតិ ដែលត្រូវកំនត់ដោយសន្និសីទបណ្តាភាគី ។

៤. ក្នុងសម័យប្រជុំទី ១ របស់ខ្លួន សន្និសីទបណ្តាភាគីសំរាប់ជាការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ត្រូវអនុម័ត និងត្រូវពិនិត្យឡើងវិញជាប្រចាំនៅពេលក្រោយ នូវគោលការណ៍សំរាប់រៀបចំព័ត៌មានចាំបាច់តាមមាត្រានេះ ដោយគិតទាំងគោលការណ៍សំរាប់រៀបចំរបាយការណ៍ជាតិរបស់បណ្តាភាគីក្នុងឧបសម្ព័ន្ធ ១ តាមការអនុម័តដោយសន្និសីទបណ្តាភាគី ។ មុនដំនាក់កាលទី ១ នៃការសន្យា សន្និសីទបណ្តាភាគីសំរាប់ជាការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ក៏ត្រូវធ្វើសេចក្តីសំរេចអំពីវិធីសំរាប់ធ្វើការគណនាបរិមាណកំនត់ ។

## មាត្រា ៨

១. ព័ត៌មានដែលដាក់ជូនតាមមាត្រា ៧ ដោយភាគីនីមួយៗក្នុងឧបសម្ព័ន្ធ ១ ត្រូវទទួលការពិនិត្យវាយតំលៃដោយក្រុមជំនាញការអនុលោមតាមសេចក្តីសំរេចនៃសន្និសីទបណ្តាភាគី និងយោងតាមគោលការណ៍អនុម័តដោយសន្និសីទបណ្តាភាគីសំរាប់ជាការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ តាមវាក្យខ័ណ្ឌ ៤ ខាងក្រោម ។ ព័ត៌មានដាក់ជូនតាមមាត្រា ៧ វាក្យខ័ណ្ឌ ១ ដោយភាគីក្នុងឧបសម្ព័ន្ធ ១ នឹងត្រូវពិនិត្យឡើងវិញ ជាចំណែកមួយនៃការប្រមូលផ្តុំ និងផ្ទៀងផ្ទាត់លើការធ្វើសារពើភ័ណ្ឌអេមីស្យុង និងបរិមាណកំនត់ ។ លើសពីនេះ ព័ត៌មាន ដែលដាក់ជូនតាមមាត្រា ៧ វាក្យខ័ណ្ឌ ២ ដោយភាគីក្នុងឧបសម្ព័ន្ធ ១ នឹងត្រូវពិនិត្យឡើងវិញ ជាចំណែកមួយនៃការពិនិត្យរបាយការណ៍ ។

២. លេខធិការដ្ឋានត្រូវសំរបសំរួលជាមួយក្រុមជំនាញការ ដែលជ្រើសរើសចេញពីបណ្តាជំនាញការចាត់តាំងដោយបណ្តាភាគីក្នុងអនុសញ្ញានេះ និងដោយអង្គការអន្តររដ្ឋាភិបាលយោងតាមការណែនាំពីសំណាក់សន្និសីទបណ្តាភាគី ។

៣. ដំនើរការពិនិត្យឡើងវិញត្រូវតែជាការវាយតំលៃបច្ចេកទេសម៉ត់ចត់ និងល្អិតល្អន់លើគ្រប់ទិដ្ឋភាពនៃការប្រតិបត្តិរបស់បណ្តាភាគីក្នុងពិធីសារនេះ ។ ក្រុមជំនាញការត្រូវរៀបចំរបាយការណ៍ទៅសន្និសីទបណ្តាភាគីសំរាប់ជាការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ដោយវាយតំលៃកិច្ចអនុវត្តន៍ការសន្យានៃភាគីនីមួយៗ និងធ្វើអត្តសញ្ញាណបញ្ហាក្នុងការអនុវត្តន៍ និងកត្តាជះឥទ្ធិពលដល់ការអនុវត្តន៍ ។ លេខាធិការដ្ឋានត្រូវចែករបាយការណ៍បែបនេះឱ្យដល់គ្រប់បណ្តាភាគីក្នុងអនុសញ្ញានេះ ។ លេខាធិការដ្ឋានត្រូវធ្វើបញ្ជីសំនួរពាក់ព័ន្ធនឹងការប្រតិបត្តិដែលមានបញ្ជាក់ក្នុងរបាយការណ៍បែបនេះ សំរាប់ការពិចារណាបន្ថែមទៀតពីសំណាក់សន្និសីទបណ្តាភាគីសំរាប់ជាការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ។

៤. ក្នុងសម័យប្រជុំទី ១ របស់ខ្លួន សន្និសីទបណ្តាភាគីសំរាប់ជាការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ តាមរយៈក្រុមជំនាញការ ត្រូវអនុម័ត និងពិនិត្យឡើងវិញជាទៀតទាត់នៅពេលក្រោយបន្ទាប់មកទៀត នូវគោលការណ៍សំរាប់ពិនិត្យឡើងវិញការប្រតិបត្តិតាមពិធីសារនេះ ដោយផ្អែកលើគ្រប់សេចក្តីសំរេចរបស់សន្និសីទបណ្តាភាគី ។

៥. ដោយមានជំនួយពីអង្គភាពជំនួយការអនុវត្ត (Subsidiary Body on Implementation) និងក្នុងករណីសមស្របពីអង្គភាពជំនួយការផ្តល់យោបល់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (Subsidiary Body on Scientific and Technological Advice) សន្និសីទបណ្តាភាគីសំរាប់ជាការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះត្រូវពិចារណា :

(ក) ព័ត៌មានដែលដាក់ជូនដោយបណ្តាភាគីតាមមាត្រា៧ និងរបាយការណ៍ពីក្រុមជំនាញការធ្វើឡើងតាមមាត្រានេះ ។

(ខ) បណ្តាសំនួរពាក់ព័ន្ធនឹងការអនុវត្តន៍ដែលស្រង់ជាបញ្ជីដោយលេខាធិការដ្ឋានតាមវាក្យខ័ណ្ឌ៣ខាងលើ ក៏ដូចជាបណ្តាសំនួរលើកឡើងដោយភាគី ។

៦. អនុលោមតាមការពិចារណារបស់ខ្លួនអំពីព័ត៌មានដែលយោងក្នុងវាក្យខ័ណ្ឌ ៥ ខាងលើ សន្និសីទបណ្តាភាគីសំរាប់ជាការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះត្រូវធ្វើសេចក្តីសំរេចលើបញ្ហាចាំបាច់ណាមួយសំរាប់អនុវត្តពិធីសារនេះ ។

## មាត្រា ៩

១. សន្និសីទបណ្តាភាគីសំរាប់ជាការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះត្រូវពិនិត្យពិធីសារនេះឡើងវិញជាទៀងទាត់ ដោយផ្អែកលើពត៌មាន និងការវាយតំលៃវិទ្យាសាស្ត្រអំពីការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់របស់វា ក៏ដូចជាពត៌មានពាក់ព័ន្ធនឹងបច្ចេកទេស សង្គម និងសេដ្ឋកិច្ច ។ ការពិនិត្យឡើងវិញបែបនេះត្រូវតែមានការសំរបសំរួលជាមួយការពិនិត្យឡើងដែលពាក់ព័ន្ធក្នុងក្របខ័ណ្ឌនៃអនុសញ្ញា ជាពិសេសការពិនិត្យឡើងវិញដូចមានចែងក្នុងមាត្រា ៤ វាក្យខ័ណ្ឌ ២ (ឃ) និងមាត្រា ៧ វាក្យខ័ណ្ឌ ២ (ក) នៃអនុសញ្ញា ។ ផ្អែកលើការពិនិត្យឡើងវិញទាំងនេះ សន្និសីទបណ្តាភាគីសំរាប់ជាការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ត្រូវចាត់វិធានការសមស្រប ។

២. ការពិនិត្យឡើងវិញលើកទី ១ ត្រូវធ្វើនៅក្នុងសម័យប្រជុំលើកទី ២ នៃសន្និសីទបណ្តាភាគីសំរាប់ជាការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ។ ការពិនិត្យឡើងវិញលើកក្រោយទៀត ត្រូវធ្វើជាទៀងទាត់នៅចន្លោះពេល និងតាមកាលវេលាកំនត់ ។

## មាត្រា ១០

ដោយយោងតាមការទទួលខុសត្រូវរួម និងខុស១គ្នារបស់ខ្លួន តាមគោលបំណង កាលៈទេសៈ និងអាទិភាពអភិវឌ្ឍន៍ជាក់លាក់សំរាប់ជាតិ និងប្រចាំតំបន់របស់ខ្លួន និងដោយពុំមានការដាក់បញ្ចូលបន្ថែមនូវការសន្យាថ្មីណាមួយសំរាប់បណ្តាភាគីពុំមានក្នុងឧបសម្ព័ន្ធ ១ ប៉ុន្តែដោយអះអាងជាថ្មីឡើងវិញនូវការសន្យាដែលមានស្រាប់តាមមាត្រា ៤ វាក្យខ័ណ្ឌ ១ អំពីការសន្យាដើម្បីសំរេចការអភិវឌ្ឍន៍ដោយចិរភាព និងដោយយោងតាមមាត្រា ៤ វាក្យខ័ណ្ឌ ៥ និង ៧ បណ្តាភាគីក្នុងអនុសញ្ញានេះត្រូវ :

ក) ក្នុងករណីដែលពាក់ព័ន្ធ និងតាមការដែលអាចធ្វើបាន រៀបចំកម្មវិធីដែលមានប្រសិទ្ធិភាពសេដ្ឋកិច្ចសំរាប់ជាតិ និងក្នុងករណីសមស្រប រៀបចំកម្មវិធីសំរាប់តំបន់ ដើម្បីកែលំអគុណភាពកត្តាអេមីស្យុងនៅក្នុងមូលដ្ឋាន ទិន្នន័យពីសកម្មភាព និង/ឬបណ្តុំគំរូដែលឆ្លុះបញ្ចាំងលក្ខខណ្ឌសេដ្ឋកិច្ចសង្គមនៃភាគីនីមួយ១ ដើម្បីរៀបចំនិងកែតំរូវជាទៀងទាត់ឱ្យទាន់សភាពការណ៍នូវសារពើភ័ណ្ឌជាតិនៃអេមីស្យុងដោយសកម្មភាពមនុស្សតាមប្រភពផ្សេង១ និងការចាប់យកតាមរយៈអាងស្រូបឧស្ម័នផ្ទះកញ្ចក់ទាំងអស់ ដែលពុំមានចែងក្នុងពិធីសារក្រុងម៉ុងរ៉េអាល់ ដោយប្រើប្រាស់វិធីសាស្ត្រដែលអាចប្រៀបធៀបបាន និងដែលមានការអនុម័តដោយសន្និសីទបណ្តាភាគី ព្រមទាំងស្របគ្នាជាមួយគោលការណ៍សំរាប់រៀបចំរបាយការណ៍ជាតិ ដែលមានការអនុម័តដោយសន្និសីទបណ្តាភាគី ។

ខ) រៀបចំ អនុវត្ត បោះពុម្ពផ្សាយ និងកែតំរូវជាទៀងទាត់ឱ្យទាន់សភាពការណ៍ នូវកម្មវិធីជាតិ និងក្នុងករណីសមស្រប ត្រូវធ្វើដូចគ្នាសំរាប់តំបន់ នូវកម្មវិធីដែលមានដាក់បញ្ចូលវិធានការដើម្បីសំរាលការប្រែប្រួលអាកាសធាតុ និងបណ្តាវិធានការសំរួលសំរាប់ឱ្យមានបន្សាំបានសមស្រប ទៅនឹងការប្រែប្រួលអាកាសធាតុ ។

(i) កម្មវិធីបែបនេះដែលពាក់ព័ន្ធនឹងវិស័យថាមពល ដឹកជញ្ជូន និងឧស្សាហកម្ម ក៏ដូចជាវិស័យកសិកម្ម ព្រៃឈើ និងការគ្រប់គ្រងសំណល់ ។ លើសពីនេះ បច្ចេកវិទ្យា និងវិធីសាស្ត្របន្សាំសំរាប់កែលំអ ការរៀបចំផែនការ នឹងជួយធ្វើឱ្យប្រសើរឡើងនូវភាពស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ ។

(ii) ភាគីក្នុងឧបសម្ព័ន្ធ ១ ត្រូវដាក់ជូនពត៌មានស្តីពីសកម្មភាពក្នុងក្របខ័ណ្ឌនៃពិធីសារនេះ រួមទាំងកម្មវិធីជាតិ អនុលោមតាមមាត្រា ៧ និងក្នុងករណីសមស្រប បណ្តាភាគីដទៃទៀតត្រូវព្យាយាមដាក់បញ្ចូលក្នុងរបាយការណ៍ជាតិរបស់ខ្លួននូវពត៌មានស្តីពីកម្មវិធីដែលមានរួមបញ្ចូលវិធានការ ដែលបណ្តាភាគីជឿថា អាចរួមចំណែកដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់របស់វា រួមទាំងការកាត់បន្ថយកំនើនអេមីស្យុងឧស្ម័នផ្ទះកញ្ចក់ និងបង្កើនការចាប់យកតាមរយៈអាងស្រូបកាបូន ការកសាងសមត្ថភាពបច្ចេកទេស និងវិធានការបន្សាំ ។

គ) សហការក្នុងការជំរុញបង្កើតវិធីប្រកបដោយប្រសិទ្ធិភាពសំរាប់អភិវឌ្ឍ អនុវត្ត និងផ្សព្វផ្សាយ ព្រមទាំងចាត់រាល់វិធានការដែលអាចធ្វើបាន ដើម្បីជំរុញ សំរួល និងក្នុងករណីសមស្រប ផ្តល់ហិរញ្ញវត្ថុ ផ្ទេរបច្ចេកវិទ្យា ឬលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យាសមស្របនឹងលក្ខខណ្ឌបរិស្ថាន ជំនាញ បទពិសោធន៍ និងដំណើរការពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ជាពិសេសសំរាប់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ រួមទាំងការរៀបចំគោលនយោបាយ និងកម្មវិធីសំរាប់ការផ្ទេរដោយមានប្រសិទ្ធិភាពនូវបច្ចេកវិទ្យាសមស្របនឹងលក្ខខណ្ឌបរិស្ថាន ដែលជាកម្មសិទ្ធិសាធារណៈ ឬក្នុងការងារវិស័យសាធារណៈ និងបង្កើតលក្ខខណ្ឌបរិស្ថានសមស្របសំរាប់ការវិនិយោគឯកជន ជំរុញ និងបង្កើនការផ្ទេរ និងលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យាសមស្របនឹងស្ថានភាពបរិស្ថាន ។

ឃ) សហការស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកទេស និងជំរុញការថែទាំ និងបង្កើតប្រព័ន្ធសង្កេតការណ៍យថាភាព និងបង្កើតប័ណ្ណសារដ្ឋានទិន្នន័យ ដើម្បីកាត់បន្ថយស្ថានភាពមិនប្រាកដប្រជាពាក់ព័ន្ធនឹងប្រព័ន្ធអាកាសធាតុ ផលប៉ះពាល់បណ្តាលពីការប្រែប្រួលអាកាសធាតុ និងផលវិបាកផ្នែកសេដ្ឋកិច្ច និងសង្គម នៃយុទ្ធសាស្ត្រទប់ទល់ ព្រមទាំងជំរុញការអភិវឌ្ឍន៍ និងពង្រីង

សមត្ថភាព និងលទ្ធភាព ដើម្បីចូលរួមក្នុងកិច្ចប្រឹងប្រែងអន្តរជាតិ និងអន្តររដ្ឋាភិបាល កម្មវិធី និងបណ្តាញស្រាវជ្រាវ និងសង្កេតការណ៍យថាភាព ដោយយោងតាមមាត្រា ៥ នៃអនុសញ្ញានេះ ។

ង) សហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ និងក្នុងករណីសមស្រប ជំរុញការប្រើប្រាស់បណ្តាអង្គការដែលមានស្រាប់ ដើម្បីបង្កើត និងអនុវត្តកម្មវិធីអប់រំ និងបណ្តុះបណ្តាល រួមទាំងពង្រឹងសមត្ថភាពស្ថាប័នជាតិ ជាពិសេសសមត្ថភាពមន្ត្រី និងស្ថាប័ន និងការផ្លាស់ប្តូរ ឬជួលបុគ្គលិកឱ្យទៅបណ្តុះបណ្តាលជំនាញផ្សេងៗ ជាពិសេសសំរាប់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និងសំរបសំរួលបង្កើនការយល់ដឹងនៅកំរិតជាតិ និងបង្កើតលទ្ធភាពប្រើប្រាស់ពត៌មានពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ។ គួរបង្កើតគំរូម៉ូដែលសមស្របសំរាប់អនុវត្តសកម្មភាពទាំងនេះ តាមរយៈអង្គការដែលធ្វើការពាក់ព័ន្ធនឹងអនុសញ្ញានេះ ដោយយោងតាមមាត្រា ៦ នៃអនុសញ្ញា ។

ច) ដាក់បញ្ចូលទៅក្នុងរបាយការណ៍ជាតិរបស់ខ្លួន នូវពត៌មានស្តីពីកម្មវិធី និងសកម្មភាពដែលបានអនុវត្តអនុលោមតាមមាត្រានេះ ដោយយោងតាមសេចក្តីសំរេចពាក់ព័ន្ធនានានៃសន្និសីទបណ្តាភាគី ។

ឆ) ក្នុងពេលអនុវត្តការសន្យាតាមមាត្រានេះ ត្រូវយកចិត្តទុកដាក់ពិចារណាមាត្រា ៤ វាក្យខ័ណ្ឌ ៨ នៃអនុសញ្ញានេះ ។

## មាត្រា ១១

១. ក្នុងពេលអនុវត្តមាត្រា ១០ បណ្តាភាគីត្រូវយកចិត្តទុកដាក់ចំពោះខទាំងឡាយនៃមាត្រា ៤ វាក្យខ័ណ្ឌ ៤ ៥ ៧ ៨ និង ៩ នៃអនុសញ្ញា។

២. ក្នុងក្របខ័ណ្ឌនៃការអនុវត្តមាត្រា ៤ វាក្យខ័ណ្ឌ ១ នៃអនុសញ្ញា ដោយអនុលោមតាមខទាំងឡាយនៃមាត្រា ៤ វាក្យខ័ណ្ឌ ៣ និង មាត្រា ១១ នៃអនុសញ្ញានេះ និងតាមរយៈអង្គការ ឬបណ្តាអង្គការទទួលបន្ទុកយន្តការប្រតិបត្តិ និងហិរញ្ញវត្ថុនៃអនុសញ្ញា ភាគីបណ្តាប្រទេសឧស្សាហកម្មជឿនលឿន និងបណ្តាភាគីមានការលូតលាស់ដទៃទៀតក្នុងឧបសម្ព័ន្ធ ២ នៃអនុសញ្ញា ត្រូវ :

(ក) ផ្តល់ធនធានហិរញ្ញវត្ថុថ្មី និងបន្ថែមសំរាប់បំពេញថ្លៃចំណាយដែលបានឯកភាព និងដែលចាយដោយបណ្តាភាគីនៃប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីជួយឧបត្ថម្ភកិច្ចអនុវត្តការសន្យាដែលមានស្រាប់តាមមាត្រា ៤ វាក្យខ័ណ្ឌ ១ (ក) នៃអនុសញ្ញា ដែលមានចែងក្នុងមាត្រា ១០ វាក្យខ័ណ្ឌរង (ក) ។

(ខ) អនុលោមតាមមាត្រានោះ ផ្តល់ផងដែរនូវធនធានហិរញ្ញវត្ថុបែបនេះសំរាប់ការផ្ទេរបច្ចេកវិទ្យាចាំបាច់សំរាប់ភាគីប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីបំពេញទាំងស្រុងនូវការចំណាយបន្ថែម (incremental costs) ដែលមានការឯកភាព សំរាប់ជួយឧបត្ថម្ភកិច្ចអនុវត្តការសន្យាដែលមានស្រាប់តាមមាត្រ ៤ វាក្យខ័ណ្ឌ ១នៃអនុសញ្ញានេះ និងដែលមានចែងក្នុងមាត្រា ១០ ព្រមទាំងមានការឯកភាពរវាងភាគីប្រទេសកំពុងអភិវឌ្ឍន៍ និងអង្គការ ឬបណ្តាអង្គការអន្តរជាតិ ដែលមានយោងក្នុងមាត្រា ១១នៃអនុសញ្ញា ។

កិច្ចអនុវត្តការសន្យាដែលមានស្រាប់ទាំងនោះ ត្រូវគិតផងដែរអំពីសេចក្តីត្រូវការពិនិត្យមើលលក្ខណៈគ្រប់គ្រាន់ និងការព្យាករណ៍ចរាចរ មូលនិធិ និងសារៈសំខាន់នៃបន្ទុកសមស្របរំលែកដោយបណ្តាភាគីប្រទេសមានឧស្សាហកម្មជឿនលឿន។ ការណែនាំចំពោះអង្គការ ឬបណ្តា អង្គការទទួលបន្ទុកប្រតិបត្តិយន្តការហិរញ្ញវត្ថុនៃអនុសញ្ញានេះ ដែលពាក់ព័ន្ធនឹងដោយក្តីសំរេចនានានៃសន្និសីទបណ្តាភាគី រួមទាំងបណ្តាសេចក្តីសំរេចដែលមានការឯកភាពគ្នារួចមកហើយមុនពេលអនុម័តពិធីសារនេះ នឹងត្រូវអនុវត្តឱ្យបានសមស្របតាមការប្រែប្រួលនៅក្នុងបណ្តាប្រការនានាក្នុងមាត្រានេះដែរ ។

៣. បណ្តាភាគីនៃប្រទេសឧស្សាហកម្មជឿនលឿន និងបណ្តាភាគីដែលមានការលូតលាស់ដទៃទៀតក្នុងឧបសម្ព័ន្ធ ២ នៃអនុសញ្ញា អាចផ្តល់ធនធានហិរញ្ញវត្ថុ ហើយភាគីនៃបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ប្រើប្រាស់ធនធានហិរញ្ញវត្ថុទាំងនោះ សំរាប់អនុវត្តមាត្រា ១០ តាមរយៈកិច្ចព្រមព្រៀងទ្វេភាគី កិច្ចព្រមព្រៀងក្នុងតំបន់ និងកិច្ចព្រមព្រៀងពហុភាគីនានាផ្សេងទៀត ។

## មាត្រា ១២

១. យន្តការអភិវឌ្ឍន៍ស្អាតត្រូវបានឱ្យនិយមន័យនៅទីនេះ ។

២. គោលបំណងនៃយន្តការអភិវឌ្ឍន៍ស្អាតគឺដើម្បីជួយបណ្តាភាគីពុំមាននៅក្នុងឧបសម្ព័ន្ធ ១ ឱ្យសំរេចការអភិវឌ្ឍន៍ប្រកបដោយចិរភាព និងដើម្បីរួមចំណែកក្នុងការសំរេចគោលបំណងចុងក្រោយនៃអនុសញ្ញា ព្រមទាំងជួយបណ្តាភាគីក្នុងឧបសម្ព័ន្ធ ១ ឱ្យសំរេចបានការសន្យាកំហិត និងកាត់បន្ថយបរិមាណអេមីស្យុងស្របតាមមាត្រា ៣ ។

៣. ក្នុងក្របខ័ណ្ឌយន្តការអភិវឌ្ឍន៍ស្អាត :

(ក) បណ្តាភាគីមិនមានក្នុងឧបសម្ព័ន្ធ ១ នឹងទទួលប្រយោជន៍ពីបណ្តាសកម្មភាពគំរោងការ ដែលបង្កឱ្យអេមីស្យុងថយចុះ និង

(ខ) បណ្តាភាគីក្នុងឧបសម្ព័ន្ធ ១ អាចប្រើប្រាស់តំហយអេមីស្យុងបានពីបណ្តាសកម្មភាពនៃគំរោងការបែបនោះ ជាចំណែកមួយនៃកិច្ចបំពេញការសន្យាកំហិត និងកាត់បន្ថយបរិមាណអេមីស្យុង យោងតាមមាត្រា ៣ និងដែលកំណត់ដោយសន្និសីទបណ្តាភាគីសំរាប់ជាការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ។

៤. គោលការណ៍យន្តការអភិវឌ្ឍន៍ស្អាតត្រូវស្ថិតក្រោមអំណាច និងការណែនាំរបស់សន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ និងត្រូវត្រួតពិនិត្យដោយក្រុមប្រឹក្សាប្រតិបត្តិទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាត ។

៥. ការកាត់បន្ថយអេមីស្យុងបណ្តាលពីសកម្មភាពនៃគំរោងនិមួយៗ ត្រូវទទួលស្គាល់ដោយអង្គភាពប្រតិបត្តិដែលនឹងត្រូវចាត់តាំងដោយសន្និសីទបណ្តាភាគីសំរាប់ជាការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ដោយផ្អែកលើ :

(ក) ការចូលរួមដោយស្ម័គ្រចិត្តដែលមានការឯកភាពពីភាគីពាក់ព័ន្ធនីមួយៗ

(ខ) ផលប្រយោជន៍ពិតប្រាកដ ដែលអាចគណនាបាន និងសំរាប់រយៈពេលវែង ពាក់ព័ន្ធនឹងការសំរាលបញ្ហាប្រែប្រួលអាកាសធាតុ

(គ) កាត់បន្ថយអេមីស្យុងបន្ថែមលើកំរិតបច្ចុប្បន្នណាមួយដែលមានស្រាប់ក្នុងករណីអវត្តមាននៃសកម្មភាពគំរោងការខាងលើ ។

៦. យន្តការអភិវឌ្ឍន៍ស្អាតនេះត្រូវជួយចាត់ចែងផ្តល់មូលនិធិសំរាប់សកម្មភាពគំរោងការដែលបានការទទួលស្គាល់ តាមការចាំបាច់ ។

៧. នៅក្នុងសម័យប្រជុំលើកទី១របស់ខ្លួន សន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ត្រូវបរិយាយឱ្យបានលំអិតពីវិធី និងបែបបទប្រកបដោយគោលបំណងដើម្បីធានាតំលាភាព ប្រសិទ្ធិភាព និងការទទួលខុសត្រូវ តាមរយៈសវនកម្ម និងផ្ទៀងផ្ទាត់ដោយអង្គភាពឯករាជ្យ សំរាប់សកម្មភាពគំរោងការ ។

៨. សន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ត្រូវធានាថា ចំណែកនៃចំណូលបានពីសកម្មភាពនៃគំរោងការខាងលើនឹងត្រូវប្រើប្រាស់សំរាប់បំពេញចំណាយរដ្ឋបាល និងសំរាប់ជួយភាគីប្រទេសកំពុងអភិវឌ្ឍន៍ ពិសេសបណ្តាប្រទេសដែលងាយរងគ្រោះដោយឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ ក្នុងការបំពេញចំនាយសំរាប់បន្សាំនឹងស្ថានភាពប្រែប្រួលអាកាសធាតុ ។

៩. ការចូលរួមក្នុងក្របខ័ណ្ឌយន្តការអភិវឌ្ឍន៍ស្អាត រួមទាំងសកម្មភាពចែងក្នុងវាក្យខ័ណ្ឌ ៣ (ក) ខាងលើ និងបណ្តាសកម្មភាពទទួលយកនូវការកាត់បន្ថយអេមីស្យុង អាចអនុញ្ញាតឱ្យមានការចូលរួមពីសំណាក់អង្គភាពឯកជន ឬសាធារណៈ និងត្រូវស្ថិតក្រោមរាល់ការណែនាំ ដែលអាចនឹងដាក់ចេញដោយក្រុមប្រឹក្សាប្រតិបត្តិទទួលបន្ទុកការងារយន្តការអភិវឌ្ឍន៍ស្អាត ។

១០. ការកាត់បន្ថយអេមីស្យុង ដែលមានការទទួលស្គាល់នៅក្នុងចន្លោះឆ្នាំ ២000 រហូតដល់ពេលចាប់ផ្តើមដំណាក់កាលទី ១ នៃការសន្យា អាចប្រើប្រាស់សំរាប់ជួយសំរេចការសន្យា នៅក្នុងដំនាកកាលទី ១ នៃការសន្យា ។

## **មាត្រា ១៣**

១. សន្និសីទបណ្តាភាគី ដែលជាស្ថាប័នជាន់ខ្ពស់នៃអនុសញ្ញា ត្រូវមាននាទីជាកន្លែងប្រជុំសំរាប់បណ្តាភាគីក្នុងពិធីសារនេះ ។

២. បណ្តាភាគីក្នុងអនុសញ្ញា ដែលមិនមែនជាភាគីក្នុងពិធីសារនេះ អាចចូលរួមជាអ្នកសង្កេតការណ៍ ក្នុងសម័យប្រជុំណាមួយនៃសន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ។ នៅក្នុងសន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ មានតែបណ្តាភាគីក្នុងពិធីសារនេះទេដែលអាចធ្វើសេចក្តីសំរេចក្នុងក្របខ័ណ្ឌនៃពិធីសារនេះ ។

៣. នៅក្នុងសន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ សមាជិកណាម្នាក់ក្នុងការិយាល័យសន្និសិទបណ្តាភាគី ដែលជាតំណាងភាគីមួយក្នុងអនុសញ្ញានេះនៅក្នុងពេលសន្និសីទ ប៉ុន្តែមិនជាភាគីក្នុងពិធីសារនេះ នឹងត្រូវជំនួសដោយសមាជិកម្នាក់បន្ថែមទៀត តាមរយៈការបោះឆ្នោតដោយ និងត្រូវជ្រើសរើសក្នុងចំណោមបណ្តាសមាជិកក្នុងពិធីសារនេះ ។

៤. សន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ត្រូវពិនិត្យឡើងវិញជាទៀងទាត់នូវការអនុវត្តន៍ពិធីសារនេះ និងត្រូវធ្វើសេចក្តីសំរេចចាំបាច់ក្នុងក្របខ័ណ្ឌនៃអណត្តិរបស់ខ្លួន ដើម្បីជំរុញប្រសិទ្ធិភាពនៃការអនុវត្តន៍ពិធីសារនេះ ។ សន្និសិទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ត្រូវបំពេញមុខងាររបស់ខ្លួនដែលកំនត់ដោយពិធីសារនេះ ហើយត្រូវ :

(ក) ផ្អែកលើមូលដ្ឋាននៃពត៌មានដែលមាន និងស្របតាមខចែងក្នុងពិធីសារនេះ វាយតំលៃការអនុវត្តន៍ពិធីសារនេះរបស់បណ្តាភាគី ផលសរុបបានពីបណ្តាវិធានការអនុវត្ត អនុលោមតាមពិធីសារនេះ ពិសេសផ្នែកបរិស្ថាន សេដ្ឋកិច្ច និងសង្គម ក៏ដូចជាផលប៉ះពាល់ត្រួតគ្នា និងវិសាលភាពនៃការសំរេចបាននូវគោលបំណងរបស់អនុសញ្ញានេះ ។

(ខ) ពិនិត្យជាទៀងទាត់នូវ កាតព្វកិច្ចរបស់បណ្តាភាគីក្នុងពិធីសារនេះ ដោយផ្តោតការយកចិត្តទុកដាក់ចំពោះរាល់ការពិនិត្យកែសំរួលដែលមានកំនត់ក្នុងមានត្រា ៤ វាក្យខណ្ឌ ២ (ឃ) និងមាត្រា ៧ វាក្យខ័ណ្ឌ ២ នៃអនុសញ្ញា និងដោយផ្អែកលើគោលបំណងនៃអនុសញ្ញា ហើយពិនិត្យជាទៀងទាត់នូវបទពិសោធន៍ទទួលបានក្នុងការអនុវត្តន៍ និងការវិវត្តន៍រីកចំរើននៃចំណេះដឹងខាងវិទ្យាសាស្រ្ត និងបច្ចេកវិទ្យា ដោយក្នុងនេះដែរត្រូវពិចារណា និងអនុម័តរបាយការណ៍ប្រក្រតីស្តីពីការអនុវត្តន៍ពិធីសារនេះ ។

(គ) ជំរុញ និងសំរួលការផ្លាស់ប្តូរពត៌មានស្តីពីវិធានការអនុម័តដោយបណ្តាភាគី សំរាប់ដោះស្រាយការប្រែប្រួលអាកាសធាតុ និងផលរបស់វា ដោយគិតទាំងភាពខុសគ្នានៃកាលៈទេសៈ ការទទួលខុសត្រូវ និងសមត្ថភាពរបស់បណ្តាភាគី ព្រមទាំងបណ្តាការសន្យារៀង១ខ្លួនរបស់ភាគីទាំងនោះ ក្នុងក្របខ័ណ្ឌនៃពិធីសារនេះ ។

(ឃ) តាមសំនើរបស់ភាគីពីរ ឬច្រើន ត្រូវជួយសំរបសំរួលវិធានការអនុម័តដោយភាគីទាំងនោះ សំរាប់ដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ និងផលរបស់វា ដោយគិតទាំងភាពខុសគ្នានៃកាលៈទេស ការទទួលខុសត្រូវ និងសមត្ថភាពរបស់បណ្តាភាគី ព្រមទាំងការសន្យារបស់ពួកគេរៀងខ្លួនរបស់ភាគីទាំងនោះ ក្នុងក្របខ័ណ្ឌនៃពិធីសារនេះ ។

(ង) អនុលោមតាមគោលបំណងនៃអនុសញ្ញានេះ និងខនានាក្នុងពិធីសារនេះ និងដោយផ្អែកលើបណ្តាសេចក្តីសំរេចពាក់ព័ន្ធធ្វើដោយសន្និសីទនៃបណ្តាភាគី ត្រូវជំរុញ និងណែនាំការអភិវឌ្ឍន៍ និងធ្វើឱ្យប្រសើរឡើងនូវតាមកាលកំណត់ នូវវិធីសាស្ត្រដែលអាចប្រៀបធៀបបាននូវប្រសិទ្ធិភាពនៃការអនុវត្តន៍ពិធីសារនេះ និងត្រូវមានការឯកភាពពីសំណាក់សន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ។

(ច) ធ្វើអនុសាសន៍ទាក់ទងនឹងបញ្ហានានាចាំបាច់សំរាប់អនុវត្តពិធីសារនេះ ។

(ឆ) ប្រឹងប្រែងឱ្យមានការរួបរួមធនធានហិរញ្ញវត្ថុ អនុលោមតាមមាត្រា ១១ វាក្យខ័ណ្ឌ ២ ។

(ជ) បង្កើតអង្គភាពជំនួយការតាមការចាំបាច់សំរាប់អនុវត្តពិធីសារនេះ ។

(ឈ) ក្នុងករណីសមស្រប ស្វែងរក និងប្រើប្រាស់បណ្តាសេវា និងកិច្ចសហការជាមួយ និងពិតមានផ្តល់ដោយ អង្គការអន្តរជាតិ ស្ថាប័នអន្តររដ្ឋាភិបាល និងស្ថាប័នក្រៅរដ្ឋាភិបាលដែលមានសមត្ថភាព ។

(ញ) បំពេញមុខងារផ្សេងទៀតដែលចាំបាច់សំរាប់អនុវត្តពិធីសារនេះ និងពិចារណាកិច្ចការណាមួយដែលស្តែងពីសេចក្តីសំរេចរបស់សន្និសីទបណ្តាភាគី ។

៥. បទបញ្ជានៃទំរង់បែបបទសំរាប់សន្និសីទបណ្តាភាគី និងទំរង់បែបបទហិរញ្ញវត្ថុសំរាប់ក្របខ័ណ្ឌអនុសញ្ញានេះ នឹងត្រូវអនុវត្តទៅតាមការប្រែប្រួលសមស្រប សំរាប់ពិធីសារនេះ លើកលែងតែមានការសំរេចជាមតិទូទៅដោយសន្និសិទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ។

៦. លេខាធិការដ្ឋានត្រូវកោះប្រជុំសំរាប់សម័យប្រជុំលើកទី ១ នៃសន្និសិទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ព្រមពេលជាមួយសម័យប្រជុំលើកទី ១ នៃសន្និសីទបណ្តាភាគី ដែលនឹងត្រូវកំនត់ពេលក្រោយការចូលជាធរមាននៃពិធីសារនេះ ។ សម័យប្រជុំសាមញ្ញនៃសន្និសីទបណ្តាភាគី សំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ នឹងត្រូវប្រព្រឹត្តទៅរៀងរាល់ឆ្នាំ ព្រមពេលជាមួយនឹងសម័យប្រជុំសាមញ្ញនៃសន្និសីទបណ្តាភាគី លើកលែងតែមានការសំរេចដោយសន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ។

៧. បណ្តាសម័យប្រជុំវិសាមញ្ញនៃសន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ នឹងត្រូវរៀបចំនៅពេលផ្សេង តាមការកំនត់ដោយសន្និសីទបណ្តាភាគី សំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ឬតាមសំណើរជាលាយលក្ខណ៍អក្សរដោយភាគីណាមួយយ៉ាងតិចក្នុងរយៈពេល ៦ ខែ ដើម្បីឱ្យលេខាធិការដ្ឋានធ្វើទំនាក់ទំនងជាមួយបណ្តាភាគី និងក្រោយពេលទទួលបានការគាំទ្រយ៉ាងហោចណាស់មួយភាគបីនៃបណ្តាភាគីទាំងអស់ ។

៨. អង្គការសហប្រជាជាតិ ស្ថាប័នជំនាញរបស់អង្គការនេះ និងស្ថាប័នថាមពលអាតូមិកអន្តរជាតិ ព្រមទាំងរដ្ឋជាសមាជិក ឬអ្នកសង្កេត-ការណ៍ ដែលមិនមែនជាភាគីក្នុងអនុសញ្ញានេះ អាចមានតំនាងចូលរួមក្នុងនាមជាអ្នកសង្កេតការណ៍នៅក្នុងសន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ។ ជនណាម្នាក់ ឬអង្គភាពណាមួយ ទោះបីក្នុងក្របខ័ណ្ឌជាតិឬអន្តរជាតិ រដ្ឋាភិបាល ឬមិនមែនរដ្ឋាភិបាល ដែលមានសមត្ថភាពក្នុងជំនាញដែលមានចែងក្នុងពិធីសារនេះ និងដែលបានជូនដំណឹងដល់លេខាធិការដ្ឋាន ពីគោលបំណងរបស់ខ្លួន ក្នុងការបញ្ជូនតំនាងចូលរួម ក្នុងនាមជាអ្នកសង្កេតការណ៍ ក្នុងសម័យប្រជុំនៃសន្និសីទបណ្តាភាគី សំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ អាចត្រូវបានទទួលការអនុញ្ញាតឱ្យចូលរួម លើកលែងតែមានការបដិសេធដោយភាគីមានវត្តមានក្នុងសន្និសីទ យ៉ាងហោចណាស់មួយភាគបី ។ ការអនុញ្ញាត និងការចូលរួមរបស់បណ្តាអ្នកសង្កេតការណ៍ ត្រូវគោរពទៅតាមបទបញ្ជា ដែលមានចែងក្នុងវាក្យខ័ណ្ឌ ៥ ខាងលើ ។

## មាត្រា ១៤

១. លេខាធិការដ្ឋានដែលបង្កើតឡើងតាមមាត្រា ៨ នៃអនុសញ្ញានេះ ត្រូវមានតួនាទីជាលេខាធិការដ្ឋានសំរាប់ពិធីសារនេះ ។

២. មាត្រា ៨ វាក្យខ័ណ្ឌ ២ នៃអនុសញ្ញានេះ ដែលចែងពីមុខងាររបស់លេខាធិការដ្ឋាន និងមាត្រា ៨ វាក្យខ័ណ្ឌ ៣ នៃអនុសញ្ញាដែលចែងពីការរៀបចំសំរាប់ការបំពេញមុខងាររបស់លេខាធិការដ្ឋាន នឹងត្រូវអនុវត្ត តាមការប្រែប្រួលសមស្រប សំរាប់ពិធីសារនេះ ។ លើសពីនេះ លេខាធិការដ្ឋានត្រូវបំពេញមុខងាររបស់ខ្លួន ដែលកំនត់ក្នុងក្របខ័ណ្ឌនៃពិធីសារនេះ ។

## មាត្រា ១៥

១. អង្គភាពជំនួយការផ្តល់យោបល់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងអង្គភាពជំនួយការអនុវត្ត ដែលបង្កើតឡើងតាមមាត្រា ៩ និង ១០នៃអនុសញ្ញានេះ ត្រូវមានទាទីជាអង្គភាពជំនួយការផ្តល់យោបល់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងអង្គភាពជំនួយការអនុវត្តនៃពិធីសារនេះ ។ ប្រការដែលចែងពាក់ព័ន្ធនឹងមុខងាររបស់អង្គភាពទាំងពីរនេះ ក្នុងក្របខ័ណ្ឌនៃអនុសញ្ញា ត្រូវអនុវត្ត តាមការប្រែប្រួលសមស្រប សំរាប់ពិធីសារនេះ ។ សម័យប្រជុំនៃអង្គភាពជំនួយការផ្តល់យោបល់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងអង្គភាពជំនួយការអនុវត្តនៃពិធីសារនេះ នឹងត្រូវរៀបចំរួមជាមួយការប្រជុំនៃអង្គភាពជំនួយការផ្តល់យោបល់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងអង្គភាពជំនួយការអនុវត្តនៃអនុសញ្ញានេះ ។

២. បណ្តាភាគីក្នុងអនុសញ្ញានេះ ដែលមិនមែនជាភាគីក្នុងពិធីសារនេះ អាចចូលរួមប្រជុំក្នុងនាមជាអ្នកសង្កេតការណ៍នៅក្នុងសម័យប្រជុំណាមួយនៃអង្គភាពជំនួយការ ។ នៅពេលដែលអង្គភាពជំនួយការមានទាទីជាអង្គភាពជំនួយការសំរាប់ពិធីសារនេះ មានតែបណ្តាភាគីក្នុងពិធីសារនេះទេ ដែលមានសិទ្ធិធ្វើសេចក្តីសំរេចក្នុងក្របខ័ណ្ឌនៃពិធីសារនេះ ។

៣. នៅពេលដែលអង្គភាពជំនួយការបង្កើតឡើងតាមមាត្រា ៩ និង ១០នៃអនុសញ្ញា អនុវត្តមុខនាទីរបស់ខ្លួនក្នុងការងារពាក់ព័ន្ធនឹងពិធីសារនេះ សមាជិកណាម្នាក់នៃការិយាល័យរបស់បណ្តាអង្គភាពជំនួយការទាំងនេះ ដែលធ្វើជាតំនាងភាគីមួយក្នុងអនុសញ្ញានៅក្នុងពេលប្រជុំ ប៉ុន្តែមិនមែនជាភាគីក្នុងពិធីសារនេះ ត្រូវជំនួសដោយសមាជិកម្នាក់ផ្សេងទៀតក្រោយពីមានការបោះឆ្នោតដោយ និងត្រូវជ្រើសរើសក្នុងចំណោមបណ្តាភាគីក្នុងពិធីសារនេះ ។

## មាត្រា ១៦

តាមការបន្ទាន់ដែលអាចធ្វើបាន សន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ត្រូវពិចារណាអនុវត្ត នៅក្នុងពិធីសារនេះ និងត្រូវកែប្រែក្នុងករណីសមស្រប នូវដំណើរពិគ្រោះយោបល់ពហុភាគីដែលមានយោងក្នុងមាត្រា ១៣ នៃអនុសញ្ញា ដោយផ្អែកលើរាល់សេចក្តីសំរេចដែលអាចធ្វើឡើងដោយសន្និសីទបណ្តាភាគី ។ ដំណើរពិគ្រោះយោបល់ពហុភាគីណាមួយ ដែលអាចប្រើប្រាស់នៅក្នុងពិធីសារនេះ នឹងត្រូវអនុវត្តដោយគ្មានលំអៀងនៅក្នុងទំរង់ការ និងយន្តការដែលរៀបចំដូចមានចែងក្នុងមាត្រា ១៨ ។

## មាត្រា ១៧

សន្និសីទបណ្តាភាគីត្រូវកំនត់គោលការណ៍ វិធី បទបញ្ជា និងសេចក្តីណែនាំ ជាពិសេសសំរាប់ផ្ទៀងផ្ទាត់ ធ្វើសេចក្តីរាយការណ៍ និងការទទួលខុសត្រូវក្នុងការធ្វើពាណិជ្ជកម្មអេមីស្យុង ។ បណ្តាភាគីក្នុងឧបសម្ព័ន្ធ ខ អាចចូលរួមក្នុងពាណិជ្ជកម្មអេមីស្យុង ក្នុងគោលបំណងបំពេញការសន្យាតាមមាត្រា ៣ ។ រាល់ការធ្វើពាណិជ្ជកម្មបែបនេះ ត្រូវតែជាការបន្ថែមទៅលើសកម្មភាពក្នុងប្រទេសក្នុងគោលបំណងបំពេញការសន្យាកំហិត និងកាត់បន្ថយបរិមាណអេមីស្យុងតាមមាត្រានេះ ។

## មាត្រា ១៨

នៅក្នុងសម័យប្រជុំទី ១ របស់ខ្លួន សន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ត្រូវអនុម័តទំរង់ការ និងយន្តការសមស្រប និងមានប្រសិទ្ធិភាព សំរាប់កំនត់ និងដោះស្រាយករណីខកខានមិនបានគោរពតាមខនៃពិធីសារនេះ រួមទាំងតាមរយៈការបង្កើតតារាងសន្ទស្សន៍ផលវិបាក ដោយគិតផងដែរអំពីមូលហេតុ ប្រភេទ កំរិតធ្ងន់ធ្ងរ និងភាពញឹកញាប់នៃករណីមិនគោរពតាមនេះ។ ទំរង់ការ និងយន្តការណាមួយក្នុងមាត្រានេះ ដែលតំរូវឱ្យមានការទទួលខុសត្រូវជាលក្ខណៈច្បាប់ចំពោះផលវិបាកដែលកើតឡើង នឹងត្រូវអនុម័តតាមរូបភាពនៃការធ្វើវិសោធនកម្មចំពោះពិធីសារនេះ ។

## មាត្រា ១៩

បណ្តាប្រការក្នុងមាត្រា ១៤ នៃអនុសញ្ញានេះ ដែលចែងពីដំណោះស្រាយទំនាស់ នឹងត្រូវអនុវត្ត ដោយមានការកែប្រែសមស្រប ទៅតាមស្ថានភាពនៃពិធីសារនេះ ។

## មាត្រា ២០

១. ភាគីណាមួយអាចលើកសំណើធ្វើវិសោធនកម្មចំពោះពិធីសារនេះ ។
២. ការធ្វើវិសោធនកម្មចំពោះពិធីសារនេះ នឹងត្រូវអនុម័តនៅក្នុងសម័យប្រជុំសាមញ្ញនៃសន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ។ លេខាធិការដ្ឋានត្រូវផ្សព្វផ្សាយអត្ថបទសំណើវិសោធនកម្មចំពោះពិធីសារនេះដល់បណ្តាភាគី យ៉ាងហោចណាស់ក្នុងរយៈពេល ៦ ខែ មុនពេលរៀបចំប្រជុំដើម្បីអនុម័តលើសំណើវិសោធនកម្មនោះ ។ លេខាធិការដ្ឋានត្រូវផ្សព្វផ្សាយអត្ថបទនៃសំណើវិសោធនកម្មទៅបណ្តាភាគី និងហត្ថលេខីនៃអនុសញ្ញានេះ និងផ្ញើទៅកន្លែងតំកល់ឯកសារសំរាប់ជាពត៌មាន ។
៣. បណ្តាភាគីត្រូវប្រឹងប្រែងដើម្បីឱ្យមានការឯកភាពលើសំណើវិសោធនកម្មណាមួយចំពោះពិធីសារនេះ តាមការអនុម័តដោយមតិឯកភាពជាទូទៅ ។ ក្នុងករណីដែលមិនអាចឈានដល់ការឯកភាពជាមតិទូទៅ ការអនុម័តលើសំនើធ្វើវិសោធនកម្មអាចធ្វើតាមរយៈការបោះឆ្នោតដោយសំលេងភាគច្រើនពីរភាគបីនៃបណ្តាភាគីដែលមានវត្តមាន និងដែលបានបោះឆ្នោតនៅក្នុងការប្រជុំ ។ លេខាធិការដ្ឋានត្រូវផ្ញើវិសោធនកម្មដែលទទួលបានការអនុម័តឯកភាពរួចហើយទៅកន្លែងតំកល់ឯកសារ ដែលនឹងផ្សព្វផ្សាយទៅគ្រប់បណ្តាភាគីសំរាប់ការទទួលយល់ព្រម ។
៤. ឯកសារស្តីពីការទទួលយល់ព្រមចំពោះវិសោធនកម្មនឹងត្រូវរក្សាទុកនៅកន្លែងតំកល់ឯកសារ ។ វិសោធនកម្មធ្វើឡើងតាមវាក្យខ័ណ្ឌ ៣ ខាងលើ នឹងចូលជាធរមានសំរាប់បណ្តាភាគីដែលទទួលយល់ព្រមលើវិសោធនកម្មនោះ នៅក្នុងរយៈពេល ៩០ ថ្ងៃ ក្រោយកាលបរិច្ឆេទ ដែលកន្លែងតំកល់ឯកសារបានទទួលសំណៅនៃការយល់ព្រមចំនួនយ៉ាងហោចណាស់បីភាគបួននៃចំនួនភាគីក្នុងពិធីសារនេះ ។
៥. អត្ថបទវិសោធនកម្មនឹងចូលជាធរមានសំរាប់ភាគីផ្សេងៗទៀត នៅក្នុងរយៈពេល ៩០ ថ្ងៃ ក្រោយកាលបរិច្ឆេទដែលភាគីនោះបានបញ្ជូនឯកសារស្តីពីទទួលយល់ព្រមលើវិសោធនកម្មនោះ ទៅដល់កន្លែងតំកល់ឯកសារ ។

## មាត្រា ២១

១. បណ្តាឧបសម្ព័ន្ធនៃពិធីសារនេះនឹងក្លាយជាចំណែករួមមួយនៃពិធីសារនេះ ផ្ទុយទៅវិញ ការចុះកំនត់យោងចំពោះពិធីសារនេះ នឹងត្រូវមានការចុះកំនត់យោងចំពោះឧបសម្ព័ន្ធរបស់ពិធីសារនេះផងដែរ ។ រាល់ឧបសម្ព័ន្ធដែលបានអនុម័តក្រោយពេលចូលជាធរមាននៃពិធីសារនេះ នឹងត្រូវកំនត់ក្រោមរូបភាពជាតារាង ក្រដាសបំពេញ និងជាឯកសារដែលមានទំរង់ជាសេចក្តីអធិប្បាយ ដែលមានលក្ខណៈជាឯកសារវិទ្យាសាស្ត្រ បច្ចេកទេស ឯកសារទំរង់ការ ឬឯកសាររដ្ឋបាល ។
២. គ្រប់ភាគីអាចលើកសេចក្តីស្នើឱ្យមានឧបសម្ព័ន្ធចំពោះពិធីសារនេះ និងអាចស្នើធ្វើវិសោធនកម្មចំពោះបណ្តាឧបសម្ព័ន្ធនៃពិធីសារនេះ ។
៣. បណ្តាឧបសម្ព័ន្ធចំពោះពិធីសារនេះ និងវិសោធនកម្មឧបសម្ព័ន្ធនៃពិធីសារនេះត្រូវអនុម័តក្នុងសម័យប្រជុំសាមញ្ញនៃសន្និសីទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ ។ លេខាធិការដ្ឋានត្រូវផ្សព្វផ្សាយអត្ថបទនៃសេចក្តីស្នើឧបសម្ព័ន្ធ ឬវិសោធនកម្មចំពោះឧបសម្ព័ន្ធដល់បណ្តាភាគី យ៉ាងហោចណាស់ ៦ ខែ មុនពេលប្រជុំអនុម័តសំណើនោះ ។ លេខាធិការដ្ឋានក៏ត្រូវផ្សព្វផ្សាយអត្ថបទសំនើឧបសម្ព័ន្ធ ឬវិសោធនកម្មចំពោះឧបសម្ព័ន្ធដល់បណ្តាភាគី និងហត្ថលេខីនៃអនុសញ្ញានេះនិងទៅកន្លែងតំកល់ឯកសារសំរាប់ជាពត៌មាន។
៤. បណ្តាភាគីត្រូវប្រឹងប្រែងដើម្បីឱ្យមានការឯកភាពលើសេចក្តីស្នើឧបសម្ព័ន្ធ ឬវិសោធនកម្មចំពោះឧបសម្ព័ន្ធ តាមការអនុម័តដោយមតិឯកភាពជាទូទៅ ។ ក្នុងករណីដែលមិនអាចឈានដល់ការឯកភាពជាមតិទូទៅ ការអនុម័តលើសេចក្តីស្នើឧបសម្ព័ន្ធ ឬវិសោធនកម្មចំពោះឧបសម្ព័ន្ធអាចធ្វើ តាមរយៈការបោះឆ្នោតដោយសំលេងភាគច្រើនពីរភាគបីនៃបណ្តាភាគីដែលមានវត្តមាន និងដែលបានបោះឆ្នោតនៅក្នុងការប្រជុំ ។ លេខាធិការដ្ឋានត្រូវផ្ញើឧបសម្ព័ន្ធ ឬវិសោធនកម្មចំពោះឧបសម្ព័ន្ធ ដែលទទួលបានការអនុម័តឯកភាពរួចហើយ ទៅកន្លែងតំកល់ឯកសារ ដែលនឹងផ្សព្វផ្សាយទៅគ្រប់បណ្តាភាគីសំរាប់ការទទួលយល់ព្រម ។
៥. ឧបសម្ព័ន្ធ ឬវិសោធនកម្មចំពោះឧបសម្ព័ន្ធក្រៅពីឧបសម្ព័ន្ធ A និង B ដែលបានទទួលការអនុម័តយល់ព្រម ស្របតាមវាក្យខ័ណ្ឌ ៣ និង ៤ ខាងលើ នឹងត្រូវចូលជាធរមានសំរាប់គ្រប់ភាគីក្នុងពិធីសារនេះនៅក្នុងកំឡុងពេល ៦ ខែ ក្រោយកាលបរិច្ឆេទនៃការផ្សព្វផ្សាយស្តីពីការអនុម័តឧបសម្ព័ន្ធ ឬវិសោធនកម្មចំពោះឧបសម្ព័ន្ធ ដោយកន្លែងតំកល់ឯកសារទៅគ្រប់បណ្តាភាគី លើកលែងតែចំពោះភាគី

ដែលបានធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកន្លែងតំកល់ឯកសារក្នុងកំឡុងពេលនោះ នូវការមិនទទួលយល់ព្រមរបស់គេចំពោះឧបសម្ព័ន្ធ ឬវិសោធនកម្មចំពោះឧបសម្ព័ន្ធនោះ ។ ឧបសម្ព័ន្ធ ឬវិសោធនកម្មចំពោះឧបសម្ព័ន្ធ នឹងចូលជាធរមានចំពោះបណ្តាភាគីដែល បានដកសេចក្តីជូនដំណឹងពីការមិនទទួលយល់ព្រមរបស់គេ នៅក្នុងកំឡុងពេលថ្ងៃទី ៩០ ក្រោយកាលបរិច្ឆេទ ដែលកន្លែងតំកល់ឯកសារបានទទួលសំនើសុំដកសេចក្តីជូនដំណឹងបែបនេះ ។

៦. ប្រសិនបើការអនុម័តឧបសម្ព័ន្ធ ឬវិសោធនកម្មចំពោះឧបសម្ព័ន្ធពាក់ព័ន្ធដល់ការធ្វើវិសោធនកម្មពិធីសារនេះ ឧបសម្ព័ន្ធនោះ ឬវិសោធនកម្មចំពោះឧបសម្ព័ន្ធនោះ នឹងមិនចូលជាធរមាន រហូតដល់ពេលដែលវិសោធនកម្មចំពោះពិធីសារនេះបានចូលជាធរមាន ។

៧. វិសោធនកម្មចំពោះឧបសម្ព័ន្ធ Aនិង B នៃពិធីសារនេះ នឹងត្រូវអនុម័ត និងចូលជាធរមានយោងតាមទំរង់ការដែលមានចែងក្នុងមាត្រា ២០ និងតែក្នុងករណីដែលវិសោធនកម្មចំពោះឧបសម្ព័ន្ធ B បានទទួលការអនុម័តយល់ព្រមជាលាយល័ក្សអក្សរពីសំណាក់ភាគីពាក់ព័ន្ធ។

## មាត្រា ២២

១. ភាគីនីមួយៗមានសំលេងឆ្នោតតែមួយគត់ លើកលែងតែក្នុងករណីចែងក្នុងវាក្យខ័ណ្ឌ ២ ខាងក្រោម ។

២. អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់អាចនឹងមានសិទ្ធិបោះឆ្នោតលើសពីមួយសំលេង ស្មើនឹងចំនួនរដ្ឋជាសមាជិករបស់អង្គការនោះ ដែលជាភាគីក្នុងពិធីសារនេះ ។ អង្គការបែបនេះនឹងមិនប្រើសិទ្ធិបោះឆ្នោតបែបនេះឡើយ ប្រសិនបើរដ្ឋណាមួយជាសមាជិកចូលរួមបោះឆ្នោត ក្នុងនាមជាភាគីក្នុងពិធីសារនេះ ឬផ្ទុយទៅវិញ រដ្ឋនោះនឹងពុំមានសិទ្ធិបោះឆ្នោតក្នុងនាមជាភាគីក្នុងពិធីសារនេះឡើយ ។

## មាត្រា ២៣

អគ្គលេខាធិការអង្គការសហប្រជាជាតិនឹងមាននាទីជាកន្លែងតំកល់ឯកសារពិធីសារនេះ ។

## មាត្រា ២៤

១. ពិធីសារនេះនឹងត្រូវបើកសំរាប់ការចុះហត្ថលេខា និងត្រូវមានការឱ្យសច្ចាប័ន ការទទួលយល់ព្រម ឬការអនុម័តដោយបណ្តារដ្ឋ និងអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ដែលជាភាគីក្នុងអនុសញ្ញានេះ ។ ពិធីសារនេះនឹងត្រូវបើកឱ្យចុះហត្ថលេខានៅឯទីស្នាក់ការអង្គការសហប្រជាជាតិ នៅទីក្រុងញូវយ៉ក ពីថ្ងៃទី ១៦ ខែ មិនា ឆ្នាំ ១៩៩៨ ដល់ថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ១៩៩៩ ។ ពិធីសារនេះនឹងបើកសំរាប់ការសុំចូលជាសមាជិក ចាប់ពីថ្ងៃក្រោយកាលបរិច្ឆេទបញ្ចប់ការចុះហត្ថលេខា ។ ឯកសារសច្ចាប័ន ការទទួលយល់ព្រម អនុម័ត ឬការសុំចូលជាសមាជិក នឹងត្រូវរក្សាទុកនៅកន្លែងតំកល់ឯកសារ ។

២. អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ណាមួយ ដែលក្លាយជាភាគីក្នុងពិធីសារនេះ ដោយរដ្ឋជាសមាជិករបស់ខ្លួនពុំមែនជាភាគីក្នុងពិធីសារនេះ នឹងមានកាតព្វកិច្ចជាលក្ខណៈច្បាប់តាមពិធីសារនេះទាំងស្រុង ។ ក្នុងករណីដែលបណ្តាអង្គការបែបនេះ មានរដ្ឋជាសមាជិក មួយឬច្រើនជាសមាជិកនៃពិធីសារនេះ អង្គការនេះ និងបណ្តារដ្ឋជាសមាជិករបស់ខ្លួនត្រូវធ្វើសេចក្តីសំរេចអំពីការទទួលខុសត្រូវ ក្នុងកិច្ចអនុវត្តកាតព្វកិច្ចក្នុងពិធីសារនេះ ។ ក្នុងករណីបែបនេះ អង្គការ និងរដ្ឋជាសមាជិកនឹងមិនមានសិទ្ធិទ្វេរដំណាលគ្នាក្នុងពិធីសារនេះទេ ។

៣. នៅក្នុងឯកសារសច្ចាប័ន ទទួលយល់ព្រម អនុម័ត ឬសុំចូលជាសមាជិករបស់ខ្លួន បណ្តាអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ត្រូវប្រកាសនូវកំរិតសមត្ថភាពរបស់ខ្លួនក្នុងក្របខ័ណ្ឌនៃសេចក្តីដែលមានចែងក្នុងពិធីសារនេះ ។ អង្គការទាំងនេះក៏ត្រូវធ្វើសេចក្តីជូនដំណឹងទៅកន្លែងតំកល់ឯកសារដែលនឹងផ្សព្វផ្សាយបន្តទៅបណ្តាភាគី ស្តីពីការកែប្រែ នៅក្នុងវិសាលភាពនៃសមត្ថភាពរបស់អង្គការទាំងនោះ ។

## មាត្រា ២៥

១. ពិធីសារនេះនឹងចូលជាធរមាននៅថ្ងៃទី ៩០ ក្រោយកាលបរិច្ឆេទ ដែលមានសមាជិកក្នុងអនុសញ្ញាចំនួនមិនតិចជាង ៥៥ ដែលនៅក្នុងនោះ បណ្តាភាគីក្នុងឧបសម្ព័ន្ធ ១ ដែលមានអេមីស្យុងឧស្ម័នកាបូនិចយ៉ាងហោចណាស់ ៥៥% នៃអេមីស្យុងឧស្ម័ន កាបូនិចសារុបបញ្ចេញក្នុងឆ្នាំ ១៩៩០ ដោយបណ្តាភាគីក្នុងឧបសម្ព័ន្ធ ១ បានតំកល់ឯកសារសច្ចាប័ន ទទួលយល់ព្រម អនុម័ត ឬចូលជាសមាជិក ។

២. សំរាប់តែក្នុងគោលបំណងនៃមាត្រានេះ "អេមីស្សុងឧស្ម័នកាបូនិចសរុបក្នុងឆ្នាំ ១៩៩០ បញ្ចេញដោយបណ្តាភាគីក្នុងឧបសម្ព័ន្ធ ១" មានន័យថា បរិមាណដែលបានប្រកាសឱ្យដឹងនៅកាលបរិច្ឆេទ ឬមុនកាលបរិច្ឆេទនៃការអនុម័តពិធីសារនេះ ពីសំណាក់បណ្តាភាគីក្នុងឧបសម្ព័ន្ធ ១ នៅក្នុងរបាយការណ៍ជាតិដំបូងបង្អស់ ដែលបានដាក់ជូន តាមមាត្រា ១២ នៃអនុសញ្ញា ។

៣. ចំពោះរដ្ឋនានា ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ដែលផ្តល់សច្ចាប័ន ទទួលយល់ព្រម ឬអនុម័តលើពិធីសារនេះ ឬសុំចូលជាសមាជិកនៃពិធីសារនេះក្រោយពេលដែលលក្ខខណ្ឌដែលមានចែងក្នុងវាក្យខ័ណ្ឌ ១ ខាងលើ ស្តីពីការចូលជាធរមានត្រូវបានបំពេញ ពិធីសារនេះនឹងចូលជាធរមាននៅថ្ងៃទី ៩០ ក្រោយកាលបរិច្ឆេទនៃការដាក់តំកល់លិខិតូបករណ៍សច្ចាប័ន ទទួលយល់ព្រម អនុម័ត ឬសុំចូលជាសមាជិក ។

៤. សំរាប់តែគោលបំណងនៃមាត្រានេះ លិខិតូបករណ៍ណាមួយដែលដាក់ដំកល់ដោយអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ នឹងមិនត្រូវរាប់បញ្ចូលជាចំនួនបន្ថែមនឹងចំនួនលិខិតូបករណ៍ដែលបានតំកល់ដោយបណ្តារដ្ឋជាសមាជិកនៃអង្គការនោះទេ ។

## មាត្រា ២៦

ពុំមានករណីលើកលែងណាមួយអនុញ្ញាតឱ្យមាននៅក្នុងពិធីសារនេះទេ ។

## មាត្រា ២៧

១. នៅពេលណាមួយ ក្រោយរយៈពេលបីឆ្នាំគិតចាប់ពីថ្ងៃដែលពិធីសារនេះបានចូលជាធរមានសំរាប់ភាគីណាមួយ ភាគីនោះអាចសុំដកសមាជិកភាពរបស់ខ្លួនពីពិធីសារនេះ ដោយធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកន្លែងតំកល់ឯកសារ ។

២. ការសុំលាលែងបែបនេះនឹងមានប្រសិទ្ធិភាពក្រោយពីកាលកំនត់សុពលភាពរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទដែលកន្លែងតំកល់ឯកសារបានទទួលសេចក្តីជូនដំណឹងអំពីការសុំដកសមាជិកភាពតំកល់ ឬនៅកាលបរិច្ឆេទក្រោយទៀត ដែលអាចមានកំនត់នៅក្នុងសេចក្តីជូនដំណឹងអំពីការសុំលាលែងតំកល់ ។

៣. ភាគីណាមួយដែលសុំដកសមាជិកភាពពីអនុសញ្ញា ក៏ត្រូវបានចាត់ទុកថាបានដកសមាជិកភាពពីពិធីសារនេះដែរ ។

## មាត្រា ២៨

សំណៅដើមនៃពិធីសារនេះ ដែលមានជាភាសារអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ មានតំលៃដូចគ្នា នឹងត្រូវដាក់តំកល់នៅឯអគ្គលេខាធិការអង្គកាសហប្រជាជាតិ ។

ធ្វើនៅ ក្យូតូ ថ្ងៃទីដប់មួយ ខែវិច្ឆិកា ឆ្នាំមួយពាន់ប្រាំបួនរយកៅសិបប្រាំពីរ ។

ដើម្បីជាសាក្សី បណ្តាភាគីបានចុះហត្ថលេខាលើពិធីសារនេះតាមកាលបរិច្ឆេទខាងលើ ។

## ឧបសម្ព័ន្ធ A

**ឧស្ម័នផ្ទះកញ្ចក់**

ឧស្ម័នកាបូនិច ($CO_2$)

មេតាន ($CH_4$)

ឌីអាសូតម៉ូណូអុកស៊ីត ($N_20$)

អ៊ីដ្រូភ្លុយអរ៉ូកាបូន (HFCs)

ពែរភ្លុយអរ៉ូកាបូន (PFCs)

ស៊ុលផួអិចសាក្លរីត ($SF_6$)

**វិស័យ/ ប្រភពនៃឧស្ម័នផ្ទះកញ្ចក់**

ថាមពល

- ចំហេះឥន្ធនៈ
  - ឧស្សាហកម្មថាមពល
  - ឧស្សាហកម្មផលិតឧបករណ៍ប្រើប្រាស់ និងសំណង់
  - ការដឹកជញ្ជូន
  - វិស័យផ្សេងទៀត
  - ប្រភពផ្សេងទៀត
- អេមីស្យុងពីឥន្ធនៈ
  - ឥន្ធនៈរឹង
  - ប្រេង និងឧស្ម័នធម្មជាតិ
  - ប្រភពផ្សេងទៀត

ក្នុងដំណើរផលិតកម្មឧស្សាហកម្ម

- ផលិតផលរ៉ែ
- ឧស្សាហកម្មគីមី
- ផលិតកម្មលោហធាតុ
- ផលិតកម្មផ្សេងទៀត
- ផលិតកម្មហាឡូកាបូន និងស៊ុលភួអិចសាភ្លុយអរីត
- ការប្រើប្រាស់ហាឡូកាបូន និងស៊ុលភួអិចសាភ្លុយអរីត
- ប្រភពផ្សេងទៀត

គ្រឿងរំលាយ និងការប្រើប្រាស់ផលិតផលផ្សេងទៀត

កសិកម្ម

- ដំណើររំលើងក្នុងក្រពះសត្វ
- ការគ្រប់គ្រងជីធម្មជាតិ
- វប្បកម្មស្រូវ
- ដីកសិកម្ម
- ការដុតវាលស្មៅសាវ៉ាន
- ការដុតសំណល់កសិកម្មនៅនឹងកន្លែង
- ប្រភពផ្សេងទៀត

សំណល់

- ការចោលសំណល់រឹងលើផ្ទៃដី
- ការគ្រប់គ្រងសំណល់រាវ
- ការដុតសំណល់
- ប្រភពផ្សេងទៀត

## ឧបសម្ព័ន្ធ B

| ភាគី | ការសន្យាកំហិតនិងកាត់បន្ថយបរិមាណអេមីស្យុង (ភាគរយនៃឆ្នាំមូលដ្ឋាន ឬចន្លោះពេល) |
|---|---|
| អូស្ត្រាលី | ១០៨ |
| អូទ្រីស | ៩២ |
| បែលស៊ិច | ៩២ |
| ប៊ុលហ្គារី* | ៩២ |
| កាណាដា | ៩៤ |
| ក្រូអាទី* | ៩៥ |
| សាធារណរដ្ឋឆែក* | ៩២ |
| ដាណឺម៉ាក | ៩២ |
| អេស្តូនី* | ៩២ |
| សហគមន៍អឺរ៉ុប | ៩២ |
| ហ្វាំងឡង់ | ៩២ |
| បារាំង | ៩២ |
| អាល្លឺម៉ង់ | ៩២ |
| ក្រិច | ៩២ |
| ហុងគ្រី* | ៩៤ |
| អាយស្លែន | ១១០ |
| អៀកឡង់ | ៩២ |
| អ៊ីតាលី | ៩២ |
| ជប៉ុន | ៩៤ |
| ឡាទ្វី* | ៩២ |
| លីកេនស្តេន | ៩២ |
| លីទុយអានី* | ៩២ |
| លុចសំបួរ | ៩២ |
| ម៉ូណាកូ | ៩២ |
| ហូឡង់ | ៩២ |
| នូវែលសេឡង់ | ១០០ |
| ណ័រវេ | ១០១ |
| ប៉ូឡូញ* | ៩៤ |
| ព័រទុយហ្គាល់ | ៩២ |
| រ៉ូម៉ានី* | ៩២ |
| សហព័ន្ធរុស្ស៊ី* | ១០០ |
| ស្លូវ៉ាគី* | ៩២ |
| ស្លូវេនៀ* | ៩២ |
| អេស្ប៉ាញ | ៩២ |
| ស៊ុយអែត | ៩២ |
| ស្វីស | ៩២ |
| អ៊ុយក្រែន* | ១០០ |
| ចក្រភពអង់គ្លេស និងអៀរឡង់ខាងជើង | ៩២ |
| សហរដ្ឋអាមេរិច | ៩៣ |

--------------------

*បណ្តាប្រទេសស្ថិតក្នុងដំណើរអន្តរកាលឈានទៅសេដ្ឋកិច្ចទីផ្សារ

# សេចក្តីសំរេចអនុម័តដោយសន្និសីទបណ្តាភាគី

**(សម័យប្រជុំពេញអង្គលើកទី ១២ ថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ១៩៩៧)**

**សេចក្តីសំរេច 1/CP.3**

**ការអនុម័តពិធីសារក្រុងក្យូតូនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ**

**សន្និសីទបណ្តាភាគី**

បានពិនិត្យមាត្រា ៤ វាក្យខ័ណ្ឌ ២ (ក) និង (ខ) នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ នៅក្នុងសម័យប្រជុំទីមួយ ហើយបានសំរេចថា វាក្យខ័ណ្ឌរងទាំងអស់នេះមិនទាន់គ្រប់គ្រាន់ទេ ។

បានឃើញសេចក្តីសំរេចរបស់ខ្លួន 1/CP.1 ស្តីពី "អណត្តិក្រុងបែរឡាំង : ការពិនិត្យឡើងវិញនូវលក្ខណៈខ្វះខាតនៃមាត្រា ៤ វាក្យខ័ណ្ឌ ២ (ក) និង (ខ) នៃអនុសញ្ញានេះ រួមទាំងសំណើទាក់ទងនឹងពិធីសារ និងសេចក្តីសំរេចស្តីពីការបន្ត" ដែលមានការឯកភាពដើម្បីចាប់ផ្តើមដំណើរការសំរាប់ជួយពង្រឹងសមត្ថភាពដើម្បីចាត់វិធានការសមស្របសំរាប់ចន្លោះពេលក្រោយឆ្នាំ ២០០០ តាមរយៈការអនុម័តពិធីសារ ឬឯកសារច្បាប់ផ្សេងទៀតនៅសម័យប្រជុំលើកទី ៣ ។

បានឃើញថា គោលដៅមួយនៃដំណើរការនេះគឺដើម្បីពង្រឹងការសន្យាក្នុងមាត្រា ៤ វាក្យខ័ណ្ឌ ២ (ក) និង (ខ) នៃអនុសញ្ញានេះ សំរាប់ ប្រទេសឧស្សាហកម្មជឿនលឿន/ភាគីផ្សេងទៀត ក្នុងឧបសម្ព័ន្ធ ១ ដើម្បីថែងឱ្យបានលំអិតនូវគោលនយោបាយ និងវិធានការ និងដើម្បីកំនត់គោលបំណងនៃការកំហិត និងកាត់បន្ថយបរិមាណអេមីស្យុងនៅក្នុងកាលកំនត់មួយ ដូចជានៅឆ្នាំ ២០០៥ ២០១០ និង ២០២០ សំរាប់អេមីស្យុង និងអាងស្រូបកាបូននៃឧស្ម័នផ្ទះកញ្ចក់របស់ពួកគេ ដែលបណ្តាលពីសកម្មភាពមនុស្ស ពីប្រភពផ្សេងៗ និងដែលពុំមានចែងក្នុងពិធីសារក្រុងម៉ុងរ៉េអាល ។

បានឃើញថា យោងតាមអណត្តិក្រុងបែរឡាំង ដំណើរការនេះនឹងមិនបង្កើតការសន្យាថ្មីបន្ថែមទៀតសំរាប់បណ្តាភាគីដែលមិនមានក្នុងឧបសម្ព័ន្ធ ១ ទេ ប៉ុន្តែបានបញ្ជាក់ឡើងវិញនូវការសន្យាដែលមានស្រាប់ស្របតាមមាត្រា ៤ វាក្យខ័ណ្ឌ ១ និងបន្តអនុវត្តការសន្យាទាំងនោះដើម្បីសំរេចឱ្យបានការអភិវឌ្ឍន៍ដោយចិរភាព ដោយយោងតាមមាត្រា ៤ វាក្យខ័ណ្ឌ ៣ ៥ និង ៧ ។

បានកត់សំគាល់ បណ្តារបាយការណ៏របស់ក្រុមបណ្តោះអាសន្នទទួលបន្ទុកអណត្តិក្រុងបែរឡាំងនៅក្នុងសម័យប្រជុំទី ៨ របស់ខ្លួន [១] ។

បានពិចារណាដោយវាយតំលៃខ្ពស់នូវរបាយការណ៏បង្ហាញជូនដោយប្រធានក្រុមបណ្តោះអាសន្នទទួលបន្ទុកអណត្តិក្រុងបែរឡាំង ។

បានកត់សំគាល់ដោយវាយតំលៃខ្ពស់នូវរបាយការណ៏របស់ប្រធានគណៈកម្មាធិការអំពីលទ្ធផលទាំងមូលរបស់គណៈកម្មាធិការនេះ ។

ដោយទទួលស្គាល់តំរូវការរៀបចំដើម្បីឱ្យមានការចូលជាធរមានជាបន្ទាន់នៃពិធីសារក្រុងក្យូតូនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ។

បានដឹងថា មានសេចក្តីប្រាថ្នាចាប់ផ្តើមការងារឱ្យបានទាន់ពេល ដើម្បីផ្តល់ជាមូលដ្ឋានឱ្យមានលទ្ធផលប្រកបដោយជោគជ័យនៃសម័យប្រជុំលើកទី ៤ នៃសន្និសីទបណ្តាភាគី ដែលគ្រោងនឹងធ្វើនៅទីក្រុង ប៊ុយណូសអ៊ែ ប្រទេសអាសង់ទីន ។

១. សំរេចអនុម័តពិធីសារក្រុងក្យូតូនៃអនុសញ្ញាក្របខ័ណ្ឌអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ ដែលមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ។

២. ស្នើឱ្យអគ្គលេខាធិការអង្គការសហប្រជាជាតិមាននាទីជាកន្លែងតំកល់ពិធីសារនេះ និងត្រូវបើកសំរាប់ការចុះហត្ថលេខានៅទីក្រុងញូវយ៉ក ពីថ្ងៃទ ១៦ ខែ មិនា ឆ្នាំ ១៩៩៨ ដល់ថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ១៩៩៩ ។

៣. អញ្ជើញភាគីទាំងអស់ក្នុងអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុដើម្បីចុះហត្ថលេខាលើពិធីសារនេះ នៅថ្ងៃទី ១៦ ខែមិនា ឆ្នាំ ១៩៩៨ ឬនៅក្នុងឱកាសឆាប់បំផុត តាមដែលអាចធ្វើបាន នៅក្រោយបរិច្ឆេទនេះ និងដើម្បីតំកល់លិខិតូបករណ៏ផ្តល់សច្ចាប័ន ទទួលយល់ព្រម ឬអនុម័ត ឬចូលជាសមាជិក នៅពេលសមស្រប និងឆាប់បំផុត តាមតែអាចធ្វើបាន ។

៤. អញ្ជើញបណ្តារដ្ឋដែលមិនមែនជាភាគីក្នុងអនុសញ្ញានេះ ដើម្បីផ្តល់សច្ចាប័ន ឬទទួលយកពិធីសារនេះតាមលក្ខខណ្ឌសមស្រប ដោយជៀសវាងការពន្យាពេល ដើម្បីឱ្យរដ្ឋទាំងនោះអាចក្លាយទៅជាភាគីក្នុងពិធីសារនេះ ។

៥. ស្នើឱ្យប្រធាននៃអង្គភាពជំនួយការផ្តល់យោបល់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងប្រធានអង្គភាពជំនួយការអនុវត្ត ដោយពិចារណាអំពីថវិកាដែលបានអនុម័តសំរាប់កម្មវិធីសំរាប់រយៈពេលពីរឆ្នាំ ១៩៩៨-១៩៩៩ និងកម្មវិធីពាក់ព័ន្ធសំរាប់លេខាធិការដ្ឋាន [២] ដើម្បីផ្តល់ការណែនាំដល់លេខាធិការដ្ឋានអំពីការងាររៀបចំចាំបាច់សំរាប់ការពិចារណាពីសំណាក់សន្និសិទបណ្តាភាគី នៅក្នុងសម័យប្រជុំលើកទី ៤ របស់ខ្លួន នូវបណ្តាការងារដូចខាងក្រោម និងត្រូវកំនត់ការងារសំរាប់បណ្តាអង្គភាពជំនួយការឱ្យបានសមស្រប :

(ក) កំនត់វិធី បទបញ្ជា និងគោលការណ៏ណែនាំអំពីសកម្មភាពបង្កដោយមនុស្សពាក់ព័ន្ធនឹងការប្រែប្រួលឧស្ម័នផ្ទះកញ្ចក់ពី ប្រភពនានា និងការចាប់យកដោយអាងស្រូបកាបូនក្នុងដីកសិកម្ម និងក្នុងការប្រែប្រួលការប្រើប្រាស់ដី និងព្រៃឈើ នឹងត្រូវបន្ថែម

---

[១] FCC/AGBM/1995/2 and Corr.1, and Corr.1; FCCC/AGBM/1996/5,8, and 11; FCCC/AGBM/1997/3, 3/Add and Corr.1,5,8 and 8/Add,1.

[២] FCCC/CP/1997/INF.1.

ទៅលើ ឬកាត់ចេញពីបរិមាណកំនត់សំរាប់បណ្តាភាគីក្នុងពិធីសារនេះដែលមានក្នុងឧបសម្ព័ន្ធ ១ នៃអនុសញ្ញានេះ ដូចដែលមានចែងក្នុងមាត្រា ៣ វាក្យខ័ណ្ឌ ៤ នៃពិធីសារនេះ ។

(ខ) កំនត់និយមន័យសំរាប់គោលការណ៍ វិធី បទបញ្ជា និងគោលការណ៍ណែនាំ ជាពិសេសសំរាប់ការផ្ទៀងផ្ទាត់ ធ្វើសេចក្តីរាយការណ៍ ការគណនាពាណិជ្ជកម្មអេមីស្យុង យោងតាមមាត្រា ១៧ នៃពិធីសារនេះ ។

(គ) ចែងលំអិតអំពីគោលការណ៍ណែនាំសំរាប់ភាគីនីមួយៗក្នុងពិធីសារដែលមានក្នុងឧបសម្ព័ន្ធ ១ នៃអនុសញ្ញានេះ អំពីការផ្ទេរ ឬទទួលយកពីភាគីផ្សេងទៀត នូវចំនួនឯកត្តានៃអេមីស្យុងដែលត្រូវកាត់បន្ថយ បណ្តាលពីគំរោងការដែលមានគោលដៅកាត់បន្ថយអេមីស្យុងដោយសកម្មភាពមនុស្សពីប្រភពនានា ឬបង្កើនអាងស្រូបកាបូននៃឧស្ម័នផ្ទះកញ្ចក់ នៅក្នុងវិស័យណាមួយនៃសេដ្ឋកិច្ច ដូចមានចែងក្នុងមាត្រា ៦ នៃពិធីសារនេះ ។

(ឃ) ក្នុងលក្ខខណ្ឌសមស្រប ពិចារណាធ្វើសកម្មភាពតាមវិធីសាស្ត្រសមស្រប ដើម្បីដោះស្រាយស្ថានភាពរបស់បណ្តាភាគីក្នុងឧបសម្ព័ន្ធ B នៃពិធីសារនេះដែលក្នុងនោះគំរោងមួយអាចផ្តល់ផលប៉ះពាល់ជាបង្គួរដល់បរិមាណអេមីស្យុងនៅក្នុងចន្លោះពេលនៃការសន្យា ។

(ង) វិភាគពីផលវិបាកនៃមាត្រា ១២ វាក្យខ័ណ្ឌ ១០ នៃពិធីសារនេះ ។

៦. អញ្ជើញប្រធានអង្គភាពជំនួយការផ្តល់យោបល់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងប្រធានអង្គភាពជំនួយការអនុវត្ត ដើម្បីធ្វើសំណើរួមគ្នាទៅអង្គភាពទាំងនោះ នៅក្នុងសម័យប្រជុំលើកទី ៨ អំពីការកំនត់ការងារសំរាប់អង្គភាពទាំងនេះ សំរាប់ធ្វើការងារចាំបាច់ដើម្បីជួយបង្កលទ្ធភាពដល់សន្និសិទបណ្តាភាគីសំរាប់ការប្រជុំនៃបណ្តាភាគីក្នុងពិធីសារនេះ នៅក្នុងសម័យប្រជុំទី ១ របស់ខ្លួន ក្រោយពេលដែលពិធីសារនេះចូលជាធរមាន និងដើម្បីបំពេញមុខការដែលពិធីសារនេះបានកំនត់សំរាប់ការប្រជុំនេះ ។

## សេចក្តីសំរេច 2/CP.3

## បញ្ហាវិធីសាស្ត្រពាក់ព័ន្ធនឹងពិធីសារក្រុងក្យូតូ

**សន្និសីទបណ្តាភាគី**

បានឃើញសេចក្តីសំរេច 4/CP.1 និង 9/CP.2

ដោយគាំទ្រការសំរេចនៃអង្គភាពជំនួយការផ្តល់យោបល់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៅក្នុងសម័យប្រជុំលើកទី ៤ [១] ។

១. អះអាងឡើងវិញថាបណ្តាភាគីគួរប្រើគោលការណ៍ណែនាំសំរាប់ធ្វើសារពើភ័ណ្ឌជាតិនៃឧស្ម័នផ្ទះកញ្ចក់ របស់ក្រុមការងារអន្តរដ្ឋាភិបាលទទួលបន្ទុកកិច្ចការប្រែប្រួលអាកាសធាតុ ដែលបានកែសំរួលនៅឆ្នាំ ១៩៩៦ សំរាប់ធ្វើការប៉ាន់ប្រមាណ និងធ្វើសេចក្តីរាយការណ៍អំពីអេមីស្យុងដោយសកម្មភាពមនុស្សពីប្រភពនានា និងការចាប់យកតាមរយៈអាងស្រូបឧស្ម័នផ្ទះកញ្ចក់ ដែលពុំមានចែងក្នុងពិធីសារក្រុងម៉ុងរ៉េអាល់ ។

២. អះអាងថាអេមីស្យុងពិតប្រាកដនៃឧស្ម័នអ៊ីដ្រូភ្លុយអរ៉ូកាបូន ឧស្ម័នពែរភ្លុយអរ៉ូកាបូន និងឧស្ម័នស៊ុលភួអិចសាភ្លុយអរីដ គួរតែមានការប៉ាន់ប្រមាណក្នុងករណីដែលមានទិន្នន័យ និងប្រើប្រាស់សំរាប់ធ្វើសេចក្តីរាយការណ៍អំពីអេមីស្យុង ។ បណ្តាភាគីគួរតែប្រឹងប្រែងដើម្បីបង្កើតប្រភពទិន្នន័យ ។

៣. អះអាងឡើងវិញថាសក្តានុពលនៃកំនើនកំដៅពិភពលោក ប្រើប្រាស់ដោយបណ្តាភាគីគួរតែជាបរិមាណដែលផ្តល់ដោយក្រុមការងារអន្តររដ្ឋាភិបាលទទួលបន្ទុកកិច្ចការប្រែប្រួលអាកាសធាតុ នៅក្នុងរបាយការណ៍វាយតំលៃលើកទី២របស់ខ្លួន ("1995 IPCC GWP value") ដោយផ្អែកលើផលនៃឧស្ម័នផ្ទះកញ្ចក់សំរាប់កំឡុងពេល ១០០ ឆ្នាំ ដោយរាប់បញ្ចូលទាំងភាពមិនប្រាកដប្រជាពាក់ព័ន្ធជាច្រើនទាក់ទងនឹងការប៉ាន់ប្រមាណសក្តានុពលកំនើនកំដៅពិភពលោក ។ លើសពីនេះ ក្នុងគោលបំណងនៃការផ្តល់ពត៌មាន បណ្តាភាគីអាចប្រើប្រាស់ចន្លោះពេលមួយផ្សេង ដូចដែលមានបញ្ជាក់នៅក្នុងរបាយការណ៍វាយតំលៃលើកទី ២ ។

៤. បានឃើញថានៅក្នុងអត្ថបទកែសំរួលឆ្នាំ ១៩៩៦ នៃគោលការណ៍ណែនាំ សំរាប់ការធ្វើសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិ របស់ក្រុមការងារអន្តររដ្ឋាភិបាលទទួលបន្ទុកកិច្ចការប្រែប្រួលអាកាសធាតុ បរិមាណអេមីស្យុងកើតពីឥន្ធនៈលក់ទៅឱ្យនាវា ឬយន្តហោះសំរាប់ប្រើប្រាស់ក្នុងការដឹកជញ្ជូនអន្តរជាតិមិនគួររាប់បញ្ចូលក្នុងបរិមាណសរុបសំរាប់ប្រទេសមួយទេ ប៉ុន្តែត្រូវរាយការណ៍ដោយឡែក និងអំពាវនាវឱ្យក្រុមជំនួយការផ្តល់យោបល់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាដើម្បីធ្វើសេចក្តីលំអិតបន្ថែមស្តីពីការរាប់បញ្ចូលអេមីស្យុងទាំងនោះទៅក្នុងសារពើភ័ណ្ឌសារុបសំរាប់បណ្តាភាគី ។

៥. សំរេចថាអេមីស្យុងពីដំនើរប្រតិបត្តិការពហុភាគីអនុលោមតាមធម្មនុញ្ញសហប្រជាជាតិ នឹងមិនត្រូវរាប់បញ្ចូលទៅក្នុងបរិមាណសរុបសំរាប់ប្រទេសមួយទេ ប៉ុន្តែត្រូវរាយការណ៍ដោយឡែក រីឯអេមីស្យុងផ្សេងទៀតពាក់ព័ន្ធនឹងប្រតិបត្តិការនឹងត្រូវបញ្ចូលទៅក្នុងបរិមាណអេមីស្យុងសរុបសំរាប់ប្រទេសនៃភាគីមួយ ឬបណ្តាភាគីដែលពាក់ព័ន្ធ ។

---

[១] FCCC/SBTA/1996/20, paras, 30 and 54

## សេចក្តីសំរេច 3/CP.3
## ការអនុវត្តន៍មាត្រា ៤ វាក្យខ័ណ្ឌ ៨ និង ៩ នៃអនុសញ្ញា

**សន្និសីទបណ្តាភាគី**

កត់សំគាល់បណ្តាខក្នុងមាត្រា ៤ វាក្យខ័ណ្ឌ ៨ និង ៩ នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ។

កត់សំគាល់ផងដែរនូវខក្នុងមាត្រ ា៣ នៃអនុសញ្ញានេះ និងខក្នុងវាក្យខ័ណ្ឌ ១ (ខ) នៃ "អណត្តិក្រុងប៊ែរឡាំង "[១] ។

១. ស្នើថា នៅក្នុងសម័យប្រជុំទី ៨ របស់ខ្លួន អង្គភាពជំនួយការអនុវត្ត ត្រូវរៀបចំធ្វើអត្ថសញ្ញាណ និងកំនត់បណ្តាសកម្មភាពចាំបាច់សំរាប់បំពេញតាមតំរូវការនៃបណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៏ ដែលចែងក្នុងមាត្រា ៤ វាក្យខ័ណ្ឌ ៨ និង ៩ នៃអនុសញ្ញា ដែលកើតឡើងពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និង/ឬផលប៉ះពាល់បណ្តាលពីវិធានការឆ្លើយតប ។ បញ្ហាគួរពិចារណារួម មានវិធានការពាក់ព័ន្ធនឹងការផ្តល់មូលនិធិ ការធានារ៉ាប់រង និងការផ្ទេរបច្ចេកវិទ្យា ។

២. ស្នើផងដែរឱ្យអង្គភាពជំនួយការអនុវត្តធ្វើសេចក្តីរាយការណ៏ទៅសន្និសីទបណ្តាភាគីអំពីលទ្ធផលនៃដំណើរការនេះ នៅក្នុងសម័យប្រជុំលើកទី ៤ របស់ខ្លួន ។

៣. ស្នើឱ្យសន្និសីទបណ្តាភាគីធ្វើសេចក្តីសំរេចស្តីពីវិធានការដោយយោងតាមសេចក្តីសន្និដ្ឋាន និងអនុសាសន៏នៃដំណើរការនេះ នៅក្នុងសម័យប្រជុំលើកទី ៤ របស់ខ្លួន ។

[១] សេចក្តីសំរេច 1/CP.1.

## របាយការណ៍នៃសន្និសីទបណ្តាភាគីអំពីសម័យប្រជុំលើកទី ៣ របស់ខ្លួន

តារាង : អេមីស្យុងឧស្ម័នកាបូនិចសារុបនៃបណ្តាភាគីក្នុងឧបសម្ព័ន្ធ ១ នៅឆ្នាំ ១៩៩០
សំរាប់គោលបំណងនៃមាត្រា ២៥ នៃពិធីសារក្រុងក្យូតូ[ក]

| ភាគី | អេមីស្យុង (Gg) | |
|---|---|---|
| អូទ្រីស | ៥៩.២០០ | ភាគរយ |
| បែលស៊ិច | ១១៣.៤០៥ | ០,៤ |
| ប៊ុលហ្គារី | ៨២.៩៩០ | ០,៨ |
| កាណាដា | ៤៥៧.៤៤១ | ០,៦ |
| សាធារណរដ្ឋឆែក | ១៦៩.៥១៤ | ៣,៣ |
| ដាណឺម៉ាក | ៥២.១០០ | ១,២ |
| អូស្ត្រាលី | ២៨៨.៩៦៥ | ០,៤ |
| អេស្តូនី | ៣៧.៧៩៧ | ២,១ |
| ហ្វាំងឡង់ | ៥៣.៩០០ | ០,៣ |
| បារាំង | ៣៦៦.៥៣៦ | ០,៤ |
| អាឡឺម៉ង់ | ១.០១២.៤៤៣ | ២,៧ |
| ក្រិច | ៨២.១០០ | ៧,៤ |
| ហុងគ្រី | ៧១.៦៧៣ | ០,៦ |
| អាយស្លែន | ២.១៧២ | ០,៥ |
| អៀរឡង់ | ៣០.៧១៩ | ០,០ |
| អ៊ីតាលី | ៤២៨.៩៤១ | ០,២ |
| ជប៉ុន | ១.១៧៣.៣៦០ | ៣,១ |
| ឡាទ្វី | ២២.៩៧៦ | ៨,៥ |
| លីឆ្តិនស្តេន | ២០៨ | ០,២ |
| លុចសំបួរ | ១១.៣៤៣ | ០,០ |
| ម៉ូណាកូ | ៧១ | ០,១ |
| ហូឡង់ | ១៦៧.៦០០ | ០,០ |
| ណូវែលសេឡង់ | ២៥.៥៣០ | ១,២ |
| ន័រវេ | ៣៥.៥៣៣ | ០,២ |
| ប៉ូឡូញ | ៤១៤.៩៣០ | ០,៣ |
| ព័រទុយហ្គាល់ | ៤២.១៤៨ | ៣,០ |
| រ៉ូម៉ានី | ១៧១.១០៣ | ០,៣ |
| សហព័ន្ធរុស្ស៊ី | ២.៣៨៨.៧២០ | ១,២ |
| ស្លូវ៉ាគី | ៥៨.២៧៨ | ១៧,៤ |
| អេស្ប៉ាញ | ២៦០.៦៥៤ | ០,៤ |
| ស៊ុយអែត | ៦១.២៥៦ | ១,៩ |
| ស្វ៊ីស | ៤៣.៦០០ | ០,៤ |
| ចក្រភពអង់គ្លេសនិងអៀរឡង់ខាងជើង | ៥៨៤.០៧៨ | ០,៣ |
| សហរដ្ឋអាមេរិក | ៤.៩៥៧.០២២ | ៤,៣ |
| **សរុប** | **១៣.៧២៨.៣០៦** | ៣៦,១ |
| | | **១០០,០** |

[ក] ទិន្នន័យនេះផ្អែកលើព័តមានពីបណ្តាភាគីក្នុងឧបសម្ព័ន្ធ ១ ដែលបានដាក់ជូនរបាយការណ៍ជាតិដំបូងនៅមុន ឬនៅថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ១៩៩៧ និងត្រូវបានចងក្រងដោយលេខាធិការដ្ឋាននៅក្នុងឯកសារមួយចំនួន A/AC.237/81;FCCC/CP/1996/12/Add.2 និង FCCC/SB/1997/6) ។ របាយការណ៍មួយចំនួនមានទិន្នន័យអំពីអេមីស្យុង $CO_2$ តាមប្រភព និងការចាប់យកដោយអាងស្រូបកាបូនដោយសារការប្រែប្រួលលើការប្រើប្រាស់ដី និងព្រៃឈើ ប៉ុន្តែដោយសាររបាយការណ៍ទាំងនោះរៀបចំតាមទំរង់ផ្សេងគ្នា ទិន្នន័យទាំងនោះមិនបានដាក់បញ្ចូលនៅទីនេះទេ ។

# សទ្ទានុក្រម

| | |
|---|---|
| Ad hoc Group on the Berlin Mandate (AGBM) | ក្រុមការងារបណ្តោះអាសន្ននៃអណត្តិទីក្រុងប៊ែរឡាំង |
| Adverse effect | ផលអវិជ្ជមាន |
| Arbitration | មជ្ឈត្តវិនិច្ឆ័យ |
| Berlin Mandate | អាណត្តិទីក្រុងប៊ែរឡាំង |
| Clean development mechanism | យន្តការអភិវឌ្ឍន៏ស្អាត |
| Climate change | ការប្រែប្រួលអាកាសធាតុ |
| Climate system | ប្រព័ន្ធអាកាសធាតុ |
| Common but differentiated responsibilities | ការទទួលខុសត្រូវរួមគ្នា តែមានកំរិតផ្សេងៗគ្នា |
| Conference of the Parties (CoP) | សន្និសីទបណ្តាភាគី |
| Eligibility | ភាពអាចជ្រើសរើសយកបាន, ភាពមានសិទ្ធិទទួល |
| Emission | អេមីស្យុង, ការបញ្ចេញឧស្ម័ន |
| Emission reduction unit | ឯកតាកាត់បន្ថយអេមីស្យុង |
| Greenhouse effect | ផលផ្ទះកញ្ចក់ |
| Greenhouse gas (GHG) | ឧស្ម័នផ្ទះកញ្ចក់ |
| Intergovernmental Negotiating Committee for a Framework Convention on Climate Change (INC/FCCC) | គណៈកម្មការអន្តររដ្ឋាភិបាលដើម្បីចរចាបង្កើតអនុសញ្ញាក្របខ័ណ្ឌ ស្តីពីការប្រែប្រួលអាកាសធាតុ |
| Intergovernmental Panel on Climate Change (IPCC) | ក្រុមការងារអន្តររដ្ឋាភិបាល ស្តីពីការប្រែប្រួលអាកាសធាតុ |
| Join implementation | ការអនុវត្តន៏រួមគ្នា |
| Join fulfillment of commitments | កិច្ចអនុវត្តន៏ការសន្យារួមគ្នា |
| Least developed countries | ប្រទេសក្រីក្របំផុត |
| Legally binding commitment | ការសន្យាជាលក្ខណះច្បាប់ |
| Modalities | ទំរង់ការ ? លក្ខខណ្ឌ ? |
| National communication | របាយការណ៏ជាតិ |
| Precautionary principle | គោលការណ៏បង្ការជាមុន |
| Precursor | សារធាតុនាំមុខ |
| Prediction | ការព្យាករណ៏ |
| Projection | ចំនោល ការព្យាករណ៏ |
| Quantified emission limitation and reduction commitments | ការសន្យាកំហិត និងកាត់បន្ថយបរិមាណអេមីស្យុង |
| Regional economic integration organization | អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ |
| Reservoir | អាងផ្ទុកកាបូន |
| Sink | អាងស្រូបកាបូន |
| Source | ប្រភព |
| Systematic observation | ការសង្កេតយថាក្រម ការសង្កេតជាប្រចាំ |
| Uncertainty | ភាពមិនប្រាកដប្រជា |
| United Nations Development Programme (UNEP) | កម្មវិធីបរិស្ថានសហប្រជាជាតិ |
| World Meteorological Organisation | អង្គការឧតុនិយមពិភពលោក |